# ពង្រឹងព្រះពុទ្ធសាសនា
# នៅប្រទេសកម្ពុជា




ដោយ

ព្រះតេជព្រះគុណបណ្ឌិត **ហុក សាវណ្ណ**


ព.ស.២៥៥២ គ.ស.២០០៨

www.hoksavann.org

# មាតិកាអត្ថបទ


១. គោលបំណង ១

២. ជំហរខ្មែរនៅបរទេស ចំពោះព្រះពុទ្ធសាសនា ៥

៣. សកម្មភាពរបស់អង្គការមនុស្សធម៌ខ្លះ កំពុង
បំផ្លាញវប្បធម៌ខ្មែរ ១០

៤. អំណោយរបស់សាសនាគ្រិស្តជាអាវុធសម្លាប់
ពុទ្ធសាសនាខ្មែរ ២១

៥. ជួយខ្មែរឲ្យរស់តាមផ្លូវកាយ ប៉ុន្តែសម្លាប់វប្បធម៌ខ្មែរ
តាមផ្លូវចិត្ត ២៨

៦. អ្នកផ្សាយគ្រិស្តសាសនាខ្មែរថា ព្រះយេស៊ូជា
ព្រះសិអារ្យមេត្រី ៣០

៧. ព្រះពិតគឺព្រះពុទ្ធក្នុងព្រះពុទ្ធសាសនា ៣៥

៨. បើទទួលអំណោយមិនចូលសាសនាគ្រិស្ត
តើទទួលបាបឬទេ? ៤៧

៩. ប្រទេសកម្ពុជាមានការសម្លាប់គ្នារាប់លាននាក់
តើបណ្តាលមកពីហេតុអ្វី? ៤៨

១០. ភាពខុសគ្នានៃការប្រៀនប្រដៅឲ្យធ្វើល្អ
រវាងព្រះពុទ្ធសាសនានិងសាសនាដទៃ ៥០

១១. កាតព្វកិច្ចរបស់ព្រះសង្ឃចំពោះពុទ្ធបរិស័ទខ្មែរ ៥៤

១២. ផលប្រយោជន៍នៃការអភិវឌ្ឍន៍ព្រះពុទ្ធសាសនា
នៅតាមជាយដែនខ្មែរ ៥៧

១៣. នាទីរបស់ក្រសួងធម្មការនិងកិច្ចការសាសនា ៥៩

១៤. ព្រះពុទ្ធសាសនាចុះខ្សោយ នាំឲ្យប្រទេសកម្ពុជា
មានវិបត្តិទៅអនាគត ៦៣
១៥. អាជ្ញាធរខ្មែរគប្បីពង្រឹងពុទ្ធសាសនា ៦៥
១៦. តម្លៃរបស់ព្រះពុទ្ធសាសនា ៦៧
១៧. សេចក្ដីអំពាវនាវ ៧០

# ១- គោលបំណង

សៀវភៅដែលលោកអ្នកកំពុងអាននេះ កើតឡើងដោយមានបំណងរក្សាការពារព្រះពុទ្ធសាសនា ដែលជាព្រលឹងនិងអត្តសញ្ញាណខ្មែរឲ្យបានរឹងមាំ។ ដោយឆ្លងកាត់សង្គ្រាមជាច្រើនទសវត្សរ៍ ប្រទេសកម្ពុជាមានភាពក្រីក្រ និងទន់ខ្សោយគ្រប់វិស័យ។ លទ្ធផលសង្គ្រាមបានបន្សល់ទុកនូវក្មេងកំព្រា ស្ត្រីមេម៉ាយ មនុស្សពិការជាច្រើន។ ទិដ្ឋភាពដែលគួរឲ្យរន្ធត់នេះ បានទាញអារម្មណ៍អង្គការមនុស្សធម៌នានាក្នុងលោកបញ្ចេញនូវសប្បុរសធម៌ជួយសង្គ្រោះពលរដ្ឋខ្មែរដើម្បីជួយសម្រាលទុក្ខលំបាកទាំងនោះ។ យើងសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះសង្គហធម៌របស់អង្គការមនុស្សធម៌ទាំងនោះ។ ផ្ទុយពីនេះ គួរឲ្យស្តាយចំពោះអង្គការមនុស្សធម៌ខ្លះបានប្រព្រឹត្តផ្ទុយពីគោលបំណងដូចពោលមកហើយគឺអង្គការគ្រិស្តសាសនាបានជួយសង្គ្រោះរបៀបជានុយបញ្ឆោតខ្មែរឲ្យជឿសាសនាគ្រិស្តទៅវិញ។ អំណោយទាំងនោះ ពុំមែនជាអំណោយមនុស្សធម៌ទេ តែជាវត្ថុមានពិលពុល សម្លាប់ពុទ្ធសាសនាខ្មែរទៅវិញ។ ព្រះពុទ្ធសាសនាជាមត៌កដ៏ថ្លៃថ្លា ដែលមានតម្លៃពុំអាចកាត់ថ្លៃបានដែលដូនតាខ្មែរបានប្រគល់ឲ្យកូនចៅជំនាន់ក្រោយ។ ដូច្នេះ កូនចៅខ្មែរគប្បីនាំគ្នារក្សាការពារមត៌កនេះ ដោយមិនលះបង់ព្រលឹង

វិញ្ញាណរបស់ខ្លួនទៅជឿសាសនាគ្រិស្ត ដោយគ្រាន់តែបាន ទទួលអំណោយបន្តិចបន្តួចដែលជានុយបញ្ឆោតនោះឡើយ។ សាសនាគ្រិស្តមិនត្រឹមតែបំបែកខ្មែរផ្នែកសាសនាប៉ុណ្ណោះ ទេ គឺគេបំបែកសង្គមខ្មែរទាំងមូល បើខ្មែរណាចូលសាសនា គ្រិស្ត គេមិនឲ្យរាប់អានអ្នកកាន់ព្រះពុទ្ធសាសនា ក្រែងខ្មែរ នោះត្រឡប់ចូលកាន់ព្រះពុទ្ធសាសនាវិញ។ គេមិនឲ្យដឹង គុណមាតាបិតា ដែលជាវប្បធម៌ដ៏មានតម្លៃរបស់ខ្មែរ បែរជា ឲ្យដឹងគុណតែព្រះជាម្ចាស់របស់គេ នេះជាការបំបែករចនា សង្គមគ្រួសារខ្មែរ ធ្វើឲ្យខ្មែរបាក់បែកសាមគ្គីគ្នា។ ពីមុនមក ខ្មែរសាមគ្គីគ្នាដោយសារឥទ្ធិពលព្រះពុទ្ធសាសនា ខ្មែរមាន ឯកភាពខាងពុទ្ធសាសនាល្អណាស់។ ឥឡូវនេះមានសាស នាដទៃ ជាពិសេសគ្រិស្តសាសនាមកញុះញង់បំបែកបំបាក់ ខ្មែរឲ្យខ្មែរបែកបាក់សាមគ្គីគ្នា។

កលល្បិចនៃសាសនាគ្រិស្ត ដែលគេយកមកប្រើមាន ច្រើនយ៉ាង ដើម្បីអូសទាញយុវជនខ្មែរឲ្យជឿសាសនាគ្រិស្ត ដោយវិធីបង្រៀនភាសាអង់គ្លេស ហើយឆ្លៀតបង្រៀនសាស នាគ្រិស្តផង ដោយយកអំណោយទៅចែក ឆ្លៀតឃោសនា សាសនាគ្រិស្តផង។ គេផ្សាយទៅលើកូនក្មេងខ្មែរជាអនីតិ ជន ដែលជាវ័យមិនទាន់ចេះពិចារណារកការពិត ដោយប្រើ មធ្យោបាយល្បួងលោមបញ្ឆោត និងចែកនំចំណីស្ករគ្រាប់ជា ដើមធ្វើជានុយ។ ជួនកាលគេយករថយន្តមកដឹកកូនក្មេងឲ្យ

ដើរលេងកំសាន្ត និងឲ្យសប្បាយជាមួយសិល្បៈផ្សេងក្នុងផ្លូវកាមគុណ។ គេទិញទឹកចិត្តសិស្សនិស្សិតខ្លះ ដោយផ្តល់ថវិកាឲ្យរៀនសូត្រ លុះចប់គេតម្រូវឲ្យបំរើសាសនាគ្រិស្ត។ ឧទាហរណ៍ គេឲ្យជនជាតិភាគតិចនៅខេត្តរតនគិរី ចំនួន ១៦ នាក់មករៀននៅភ្នំពេញ ពេលរៀនចប់ឲ្យធ្វើជាស្នូលដឹកនាំសាសនាគ្រិស្ត ក្នុងការទាក់ទាញជនជាតិភាគតិចនៅខេត្តរតនគិរីឲ្យចូលកាន់សាសនាគ្រិស្ត។ មិនតែប៉ុណ្ណោះ ភ្នាក់ងារសាសនាគ្រិស្តបានបញ្ចុះបញ្ចូលព្រះសង្ឃព្រះពុទ្ធសាសនៅវត្តមួយនាទីក្រុងភ្នំពេញថា បើព្រះអង្គសឹកទៅជួយឃោសនាឲ្យសាសនាគ្រិស្ត ពួកគេនឹងផ្តល់ប្រាក់ខែឲ្យល្មមចិញ្ចឹមជីវិតបាន តែព្រះសង្ឃនោះមានឧត្តមគតិខ្ពស់ចំពោះព្រះពុទ្ធសាសនាមិនព្រមធ្វើតាមការបញ្ចុះបញ្ចូលនោះឡើយ ។ល។

សម័យអាណានិគមនិយមបារាំង ជនជាតិខ្មែរមិនចូលកាន់សាសនាគ្រិស្តឡើយ ទោះបីបារាំងខំឃោសនាយ៉ាងខ្លាំងក្លាយ៉ាងណាក៏ដោយ។ មានចូលខ្លះតែតិចតួច ច្រើនជាជនជាតិវៀតណាម។ សម័យខ្មែរក្រហម គេបានបំបាត់ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជាដល់ឫសគល់ ប៉ុន្តែខ្មែរក្រហមមិនអាចបំបាត់ព្រលឹងវិញ្ញាណ និងមនោសញ្ចេតនារបស់ពុទ្ធសាសនិកជនខ្មែរទៅលើព្រះពុទ្ធសាសនាបានឡើយ។ ក៏ដូចគ្នានឹងសម័យសម្តេចប៉ាបជនប៉ូលទីពីរ បានចំណាយថវិការាប់រយលានដុល្លាមកផ្សាយគ្រិស្តសាសនានៅ

ក្នុងប្រទេសអាស៊ីភាគអគ្នេយ៍ ប៉ុន្តែគេមិនបានទទួលជោគជ័យនៅប្រទេសកម្ពុជាឡើយ។

ដោយចលនាកើតឡើងដូច្នេះ ទើបពេលនេះ ពុទ្ធសាសនិកជនខ្មែរមានការប្រុងប្រយ័ត្នជានិច្ច ព្រោះចលនាសាសនាគ្រិស្តនេះ បើធ្វេសប្រហែសនឹងមានគ្រោះថ្នាក់ដល់ពុទ្ធសាសនាខ្មែរ។ គ្រោះថ្នាក់មួយទៀត គឺប្រព័ន្ធច្បាប់ខ្មែរនៅតែទន់ខ្សោយ និងមិនបានអប់រំយុវជនខ្មែរជំនាន់ក្រោយបន្ថែមទៀតអំពីតម្លៃព្រះពុទ្ធសាសនាឲ្យយល់ដឹងកាន់តែច្បាស់ឡើង។ ភាពទន់ខ្សោយទាំងនេះរួមទាំងពលរដ្ឋខ្មែរសព្វថ្ងៃនេះមានភាពក្រីក្រ និងទន់ខ្សោយខាងផ្នែកបញ្ញាស្មារតីដោយសារតែសង្គ្រាមជាច្រើនទសវត្សរ៍ ភ្នាក់ងារសាសនាគ្រិស្តបានឆ្លៀតឱកាសមកផ្សាយសម្លាប់វប្បធម៌ពុទ្ធសាសនាខ្មែរ ក៏ដូចជាពួកនេះច្រើនផ្សាយនៅក្នុងប្រទេសមានវិបត្តិនិងទន់ខ្សោយខាងសេដ្ឋកិច្ច ដូចជាប្រទេសមួយចំនួននៅទ្វីបអាហ្វ្រិកនិងទ្វីបអាស៊ី ដោយសាសនានេះមិនអាចផ្សាយនៅក្នុងប្រទេសដែលជឿនលឿនដូចជាប្រទេសនៅអឺរ៉ុបបានឡើយ។ នេះជាគំនិតមិនល្អទៅលើប្រទេសតូចតាចទន់ខ្សោយ គឺមុននឹងកៀបសង្កត់ខាងផ្លូវនយោបាយ គេតែងបញ្ជូលផ្លូវសាសនាមកជាមុន។ ក្នុងទំព័រនៃសៀវភៅនេះ យើងនឹងធ្វើការវិភាគអំពីតម្លៃនៃព្រះពុទ្ធសាសនានិងចម្លើយតបទៅសាសនានេះដែលនិយាយប៉ះពាល់មកលើព្រះពុទ្ធសាសនា។

## ២- ជំហរខ្មែរនៅបរទេស ចំពោះព្រះពុទ្ធសាសនា

ពលរដ្ឋខ្មែរនៅបរទេស ដូចជាសហរដ្ឋអាមេរិក កាណាដា បារាំង និងអូស្រ្តាលីជាដើមនៅតែគោរពព្រះពុទ្ធសាសនាដដែលដូចជាពលរដ្ឋខ្មែរនៅប្រទេសកម្ពុជាជាមាតុភូមិរបស់ខ្លួនដែរ។ គេបង្កើតវត្តអារាមជាទីគោរពបូជាគ្រប់ប្រទេសដែលពួកគេស្នាក់នៅ។ គេតែងនាំគ្នាទៅវត្តពេលមានបុណ្យទានក្នុងព្រះពុទ្ធសាសនា ដូចជាបុណ្យចូលឆ្នាំខ្មែរ បុណ្យភ្ជុំបិណ្ឌ និងបុណ្យកឋិនជាដើម។ មិនតែប៉ុណ្ណោះ មានវត្តខ្លះបានបង្កើតកម្មវិធីអប់រំសីលធម៌ព្រះពុទ្ធសាសនានិងកម្មវិធីបង្រៀនអក្សរខ្មែរទៀតផង។ មានខ្មែរចូលកាន់គ្រិស្តសាសនាខ្លះ ដោយសារគេឲ្យបុណ្យសក្តិនិងប្រាក់ខែ តែមានចំនួនតិចតួចណាស់។ ក្នុងចំណោមតិចតួចនោះ មានខ្មែរខ្លះត្រឡប់មកចូលកាន់ព្រះពុទ្ធសាសនាវិញ ដោយមិនពេញចិត្តពេលដែលគេកាត់ប្រាក់ខែរបស់ខ្លួនឲ្យឧបត្ថម្ភព្រះវិហារគ្រិស្តសាសនារៀងរាល់ខែ។ បរទេសដែលធានាខ្មែរទៅ ខ្លះបង្ខំខ្មែរឲ្យជឿគ្រិស្តសាសនា ប៉ុន្តែមានខ្លះ មិនបង្ខំទេស្រេចតែខ្មែរខ្លួនឯងសម្រេចចិត្ត។ ចំពោះរឿងនេះ យើងសូមលើកយករឿងអតីតកាលអស់សំណើចមួយនៅជំរុំប្រទេសថៃ។ បុរសម្នាក់បានទទួលបារីពីបុរសម្នាក់ហើយពោលថា សូមអរគុណព្រះជាម្ចាស់ បុរសអ្នកឲ្យបារីនោះពោលតបភ្លាមថា ឲ្យបារី

មកអញវិញ ពុំមែនបារីរបស់ព្រះទេ គឺបារីរបស់អញ។ មានរឿងមួយទៀត មានបុរសម្នាក់បានរែកទឹកដាក់ពេញពាង ស្ត្រីម្នាក់ឃើញប្តីរែកទឹកពេញពាង ក៏ពោលទៅកាន់ប្តីថា សូមអរគុណព្រះជាម្ចាស់ ប្តីមានកំហឹងក៏ទាញដងរែកដេញវាយប្រពន្ធជាមួយនឹងការស្រែកគំរាមថា ឯងខំរែកឲ្យកោងសំឡុកវាមិនអរគុណ បែរជាទៅអរគុណព្រះឯណាទៅវិញ។ រឿងនេះកើតឡើងនៅជំរុំខៅអីដាងប្រទេសថៃពេលដែលបុ-រសនិងស្ត្រីខ្មែរនោះទៅរៀនភាសាអង់គ្លេស ជាសំដីថាតាមអាចារ្យគ្រិស្ត។ បុរសដែលសុំបារីនិងស្ត្រីដែលអរគុណព្រះពេលដែលប្តីរែកទឹកពេញពាង លុះមកដល់បរទេសនៅតែកាន់ព្រះពុទ្ធសាសនាដដែល គឺគេធ្វើជាចូលសាសនាគ្រិស្តដើម្បីបានរៀនភាសាអង់គ្លេសប៉ុណ្ណោះ។ រឿងនេះ បានផ្អើលគេអស់មួយជំរុំខៅអីដាង ដោយប្រពន្ធស្រែកខ្លាំងៗថាសូមជួយខ្ញុំផង ប្តីដេញវាយខ្ញុំ ប្តីស្រែកប្រាប់អ្នកជំរុំថា សូមកុំជួយខ្ញុំវាយមីនេះឲ្យដឹងដៃម្តង ឲ្យវាហៅព្រះវាមកជួយ។ ចំណែកអ្នកសុំបារីគេក៏ខានជក់ព្រោះគេយកវិញ ដោយមិនអរគុណគេជាអ្នកឲ្យ។ ត្រង់នេះ យើងនឹកឃើញឧត្តមគតិខ្មែរក្នុងព្រះពុទ្ធសាសនាថា ធ្វើបុណ្យបានបុណ្យធ្វើបាបបានបាប ត្រង់ពាក្យថា ព្រះជាម្ចាស់ទទួលបាបមិនចូលខួរក្បាលខ្មែរឡើយបានសេចក្តីថា ខ្មែរមិនជឿសាសនាគ្រិស្តឡើយ។

ពុទ្ធសាសនិកជនខ្មែររួមជាមួយព្រះសង្ឃនៅសហរដ្ឋ

អាមេរិកជាវបានវិហារគ្រិស្តសាសនាជាច្រើនកន្លែងយកមកកែធ្វើជាវត្តព្រះពុទ្ធសាសនា។ វិហារគ្រិស្តសាសនាបានលក់វិហាររបស់ខ្លួនដោយអស់បរិស័ទគាំទ្រនិងជួយឧបត្ថម្ភ ព្រោះពុំអាចទប់ទល់នឹងការចំណាយ ដូចជាចំណាយទៅលើភ្លើងអគ្គិសនីជាដើម។ ចំណែកវត្តព្រះពុទ្ធសាសនាមិនដែលមានលក់ឈប់ធ្វើវត្តឡើយ បើមានវត្តខ្លះលក់ក៏ដើម្បីផ្លាស់ទីកន្លែងតូចចង្អៀតទៅរកទីធំទូលាយ។ ការលក់វិហារនៃសាសនាគ្រិស្តនេះ បញ្ជាក់ថា សាសនាគ្រិស្តបានត្រូវធ្លាក់ចុះគឺចុះខ្សោយបរិស័ទគាំទ្រ។ ពីដើមស្ទើរតែគ្រប់សាលារៀនសុទ្ធតែនៅក្រោមការត្រួតត្រារបស់គ្រិស្តសាសនា ឥឡូវនេះនៅក្រោមការត្រួតត្រារបស់រដ្ឋ។ មួយទៀត ពីដើមថ្ងៃអាទិត្យហាងលក់ទំនិញទាំងអស់ត្រូវបិទទ្វារមិនលក់ដូរទេ ដើម្បីទុកពេលឲ្យទៅវិហារថ្វាយបង្គំព្រះ ប៉ុន្តែឥឡូវនេះ ថ្ងៃអាទិត្យក៏បើកទ្វារលក់ស្របតាមការទាមទាររបស់អាជីវករ។ សព្វថ្ងៃនេះយុវជនជំនាន់ក្រោយនៃប្រទេសនៅអឺរ៉ុបនិងអាមេរិកមិនសូវរវីរវល់អំពីសាសនាគ្រិស្តឡើយ ព្រោះពួកគេជឿតាមលក្ខណៈវិទ្យាសាស្ត្រមានហេតុផលដែលអាចពិសោធឃើញការពិតបាន ចំណែកសាសនាគ្រិស្តពុំអាចបញ្ជាក់បាន តាមលក្ខណៈវិទ្យាសាស្ត្រឡើយ។ សភាពការណ៍កើតឡើងបែបនេះ ក៏គេមិនមានសិទ្ធិបង្ខំឡើយ ព្រោះជាប្រទេសគោរពសិទ្ធិមនុស្ស។

សព្វថ្ងៃនេះ ព្រះពុទ្ធសាសនាមានឥទ្ធិពលខ្លាំងណាស់ទៅលើប្រទេសនៅអឺរ៉ុបនិងនៅអាមេរិក មានជនជាតិនៃប្រទេសទាំងនោះចូលកាន់ព្រះពុទ្ធសាសនាច្រើនណាស់ ហើយអ្នកដែលចូលនោះភាគច្រើនជាអ្នកចេះដឹងដូចជាសាស្ត្រាចារ្យ មេធាវីជាដើម។ មុននឹងសម្រេចចិត្តចូល ពួកគេបានទៅសិក្សាព្រះពុទ្ធសាសនានៅប្រទេសស្រីលង្កា នៅភូមា នៅថៃ និងនៅឥណ្ឌា ហើយបានស្រាវជ្រាវមើលសៀវភៅព្រះពុទ្ធសាសនាជាច្រើនក្បាល ក៏យល់យ៉ាងច្បាស់ថា ព្រះពុទ្ធសាសនាមានពាក្យប្រៀប្រដៅដ៏ជ្រាល់ជ្រៅណាស់ មានហេតុផលតាមលក្ខណៈវិទ្យាសាស្ត្រ ហើយជាញាណទស្សនវិជ្ជាអាចរំដោះទុក្ខបាន។ មិនត្រឹមតែរៀនខាងទ្រឹស្តីទេ ពួកគេចូលចិត្តអនុវត្តផ្នែកវិបស្សនាការអប់រំចិត្តដើម្បីឲ្យឃើញការពិតជាខ្លឹមសាររបស់ព្រះពុទ្ធសាសនា ដើម្បីឲ្យដល់គោលដៅគឺព្រះនិព្វានជាការរំលត់ទុក្ខ។ អង្គការសហប្រជាជាតិក៏យល់តម្លៃព្រះពុទ្ធសាសនាដែលមានពាក្យប្រៀនប្រដៅដ៏មានខ្លឹមសារ គឺធម៌អហឹង្សា ការមិនបៀតបៀនដែលជាមូលដ្ឋាននៃសុខសន្តិភាពរបស់មនុស្សក្នុងលោក ហើយបានអនុម័តឲ្យធ្វើបុណ្យពិសាខបូជារបស់ព្រះពុទ្ធសាសនានៅទីស្នាក់អង្គការសហប្រជាជាតិតាំងពីថ្ងៃ១០ធ្នូ១៩៩៩។

ដូចបានពោលមកហើយ សាសនាគ្រិស្តកំពុងតែធ្លាក់ចុះនៅប្រទេសរបស់គេ ហើយព្រះពុទ្ធសាសនាកំពុងតែលូត

លាស់នៅប្រទេសទាំងនោះ។ ដូចនេះ ជនជាតិខ្មែរជាពិសេស យុវជនខ្មែរមិនគប្បីចាប់អារម្មណ៍អំពីសាសនាគ្រិស្តនេះ ឡើយ ត្រូវតែនាំគ្នារក្សាការពារព្រះពុទ្ធសាសនានេះឲ្យរឹងមាំ ថែមទៀត កុំចាញ់ការបោកបញ្ឆោតរបស់សាសនានេះ ព្រោះ គ្មានពាក្យប្រៀនប្រដៅណាមានសច្ចធម៌ដូចព្រះពុទ្ធសាសនា ឡើយ។

## ៣- សកម្មភាពរបស់អង្គការមនុស្សធម៌ខ្លះ កំពុងបំផ្លាញវប្បធម៌ខ្មែរ

យើងសង្កេតឃើញថា នៅពេលដែលប្រទេសកម្ពុជាឆ្លងពីវិបត្តិមួយទៅវិបត្តិមួយ គឺសង្គ្រាមបង្ហូរឈាម ការសម្លាប់រង្គាល ការរំលោភឈ្លានពានពីបរទេស ការរំលោភសិទ្ធិប្រជាពលរដ្ឋជាដើម បានបន្សល់ទុកនូវកុមារកំព្រា មនុស្សពិការ ស្ត្រីមេម៉ាយ ភាពអវិជ្ជាមិនចេះអក្សរ និងភាពក្រីក្រ។ ឆ្លៀតឱកាសនោះ មានអង្គការមនុស្សធម៌បរទេសនានាមកជួយសង្គ្រោះប្រជាពលរដ្ឋខ្មែរ ដែលមានទុក្ខទាំងនោះ។ អង្គការមនុស្សធម៌ទាំងនោះ មានពីរប្រភេទមានគំនិតផ្សេងគ្នា គឺអង្គការមនុស្សធម៌មួយប្រភេទ មានគំនិតបំពេញនាទីរបស់ខ្លួនស្របតាមឈ្មោះខាងលើ គឺមានករុណាធម៌អាណិតអាសូរប្រជាពលរដ្ឋខ្មែរ ដែលមានទុក្ខបានចូលទៅជួយដោយផ្តល់អំណោយមនុស្សធម៌ពិតប្រាកដទាំងខាងសម្ភារៈទាំងខាងបញ្ញាស្មារតីដោយមិនធ្វើឲ្យប៉ះពាល់ដល់វប្បធម៌របស់ជនជាតិខ្មែរឡើយ។ ផ្ទុយទៅវិញ អង្គការមនុស្សធម៌មួយប្រភេទទៀត មានសកម្មភាពផ្ទុយពីនេះ គឺធ្វើចលនាខុសពីនាទីរបស់ខ្លួន ដោយយកអំណោយខ្លះទៅចែកប្រជាពលរដ្ឋខ្មែរគ្រាន់តែជារបាំងបិទមុខ ឬជានុយសំរាប់ទាក់ទាញទឹកចិត្តប្រជាពលរដ្ឋឲ្យលះបង់សាសនាដើមរបស់ខ្លួនគឺព្រះពុទ្ធសាសនាហើយចូលកាន់សាសនាដទៃទៀត។ ក្រុមសាសនាជា

ច្រើនដែលកំពុងធ្វើចលនានៅប្រទេសកម្ពុជានោះ គេកត់សំគាល់ឃើញថា សាសនាគ្រិស្តមានចលនាខ្លាំងជាងគេ ព្រោះក្រុមសាសនានេះមានមធ្យោបាយច្រើនជាងសាសនាដទៃទៀត។ ល្បិចដែលសាសនានេះយកទៅប្រើ គឺគេយកអំណោយទៅចែក ហើយប្រាប់ប្រជាពលរដ្ឋខ្មែរថានេះជាអំណោយរបស់ព្រះជាម្ចាស់ ចូរលះបង់ព្រះពុទ្ធសាសនាហើយកាន់គ្រិស្តសាសនាវិញ បងប្អូននឹងបានអំណោយជាបន្តទៅទៀត។ កន្លែងខ្លះគេជួយព្យាបាលជម្ងឺប្រជាពលរដ្ឋខ្មែរហើយពោលថា ព្រះយេស៊ូនឹងជួយឲ្យជា ចូរនឹកដល់ព្រះជាម្ចាស់ តែបើបែរជាមិនជាស្លាប់ទៅវិញ គេជួយយកសពទៅបូជា ហើយប្រាប់គ្រួសារសពថា គ្រួសារអ្នកឯងស្លាប់ទៅបានឡើងស្ថានសួគ៌ ស្ថិតនៅជាមួយព្រះហើយ។ ពាក្យនេះផ្ទុយពីពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធគឺ ព្រះអង្គមានព្រះពុទ្ធដីកាថា សេចក្តីសុខទុក្ខចំរើនវិនាសបានសួគ៌នរកនិព្វានកើតឡើងអំពីអំពើរបស់ខ្លួន (ធម្មស្ស កោម្មិ) ពុំមែនព្រះជាម្ចាស់ឯណាទេ។ មធ្យោបាយទាក់ទាញយុវជននិងយុវនារីខ្មែរឲ្យបំភ្លេចវប្បធម៌និងទំនៀមទំលាប់ដើមរបស់ខ្លួនដែលមានព្រះពុទ្ធសាសនាជាមូលដ្ឋាន មានមិនឲ្យដឹងគុណមាតាបិតាឲ្យដឹងគុណតែព្រះជាម្ចាស់ គឺព្រះយេហូវ៉ា ដែលមានព្រះយេស៊ូជាបេសកជន ព្រោះព្រះអង្គបង្កើតអ្វីទាំងអស់។ ដូច្នេះសាសនាគ្រិស្តកំពុងតែព្យាយាមសម្លាប់ព្រលឹងខ្មែរហើយ។ មតិទូទៅ

ដែលកំពុងតែតាមដានដោយយកចិត្តទុកដាក់នោះ គឺត្រង់សាសនាគ្រិស្តកំពុងតែបំពេញសកម្មភាពដោយឥតអៀនខ្មាស់ដោយពុំកោតញញើតនឹងច្បាប់អន្តរជាតិ គឺការប្រើល្បិចល្បួងលោមកុមារខ្មែរនៅតូចដែលជាវ័យពុំទាន់ចេះពិចារណាពុំអាចទទួលខុសត្រូវតាមផ្លូវច្បាប់ឲ្យលះបង់សាសនាដូនតារបស់គេឲ្យជឿសាសនាខ្លួន។ ទង្វើនេះជាការរំលោភច្បាប់អន្តរជាតិស្តីអំពីសិទ្ធិមនុស្ស។ ក្រុមផ្សាយសាសនាគ្រិស្តគប្បីគិតថា បើមានអ្នកផ្សាយសាសនាដទៃមកល្បួងលោមអូសទាញកូនចៅរបស់ខ្លួនដែលកាន់សាសនាគ្រិស្តឲ្យទៅកាន់សាសនាដទៃវិញ ក៏ខ្លួនមិនអនុញ្ញាតឲ្យគេធ្វើដូច្នេះ ហើយនិងធ្វើវិធីទប់ទល់ដូចគ្នាដែរ ព្រោះប្រជាជាតិនីមួយៗតែងតែរក្សាការពារសាសនារបស់ខ្លួនរៀងៗខ្លួន មិនចង់ឲ្យសាសនារបស់ខ្លួនបាត់បង់ដូចគ្នា។ ក្រុមអ្នកផ្សាយសាសនាគ្រិស្តតែងឃោសនាថា ខ្លួនជាអ្នកផ្សាយដំណឹងល្អជួយមនុស្សវង្វេងដែលមិនជឿព្រះ។ ខ្លួនថាសាសនាខ្លួនល្អ គេក៏ថាសាសនាគេល្អដែរ។ ដូច្នេះ ទុកសាសនាដែលខ្លួនថាល្អនោះសំរាប់ខ្លួនឯងទៅចុះ កុំរំលោភសិទ្ធិខាងជំនឿ ដោយវិធីល្បួងលោមទឹកចិត្តបែបនេះ។ ទាក់ទងនឹងការផ្សាយគ្រិស្តសាសនានេះមានមធ្យោបាយមួយដែលអ្នកផ្សាយគ្រិស្តសាសនាយកទៅប្រើ គឺនៅជនបទមួយនៃប្រទេសថៃ ដែលសម្បូណ៌ដោយអ្នកជឿអបិយ៍ជំនឿ គឺជំនឿមិនសមហេតុផល អ្នកផ្សាយគ្រិស្តសាស

នាបានដឹងដូច្នេះ ក៏ប្រើល្បិចឲ្យមនុស្សម្នាក់ធ្វើពុតជាឈឺ ហើយឲ្យមនុស្សម្នាក់ទៀតធ្វើជាចូលរូប ឲ្យនិយាយថាអ្នកដែលឈឺនោះមកពីពុំជឿព្រះយេស៊ូ ហើយគេឲ្យគ្នាគេម្នាក់ទៅនិយាយថាឥឡូវនេះអ្នកឈឺនោះសុខចិត្តជឿព្រះយេស៊ូហើយ សូមឲ្យជាទៅ។ រំពេចនោះ គ្នាគេដែលធ្វើពុតជាឈឺនោះ ក្រោកឡើងសំដែងអាការៈថាខ្លួនជាហើយ។ ល្បិចបោកបញ្ឆោតនេះ បានធ្វើឲ្យអ្នកស្រុកថៃនៅជនបទនោះដែលពុំដឹងការពិត ក៏ចូលកាន់សាសនាគ្រិស្តមួយភាគធំ។ រឿងដូចគ្នានេះដែរ នៅស្តាតអូឡាំពិកទីក្រុងភ្នំពេញនៃប្រទេសកម្ពុជា អាចារ្យប្រដៅគ្រិស្តសាសនានិយាយឃោសនាថា ព្រះយេស៊ូជួយមនុស្សខ្វាក់ឲ្យភ្លឺ មនុស្សគឲ្យចេះនិយាយបាន មនុស្សថ្លង់ឲ្យស្តាប់បានជាដើម។ និយាយមិនបានប៉ុន្មានម៉ាត់ផងកំហឹងប្រជាពលរដ្ឋខ្មែរអ្នកស្តាប់បានកើតឡើង ដោយសង្កេតឃើញការពុំពិត ក៏ធ្វើសកម្មភាពអំពើហឹង្សាដុតពាក្យស្លោកដែលបិទជុំវិញស្តាត លោកអាចារ្យគ្រិស្តរត់គេចខ្លួនស្ទើរតែមិនទាន់។ តាមពិត ព្រះពុទ្ធសាសនាមិនត្រូវប្រើអំពើហឹង្សាទេ ប៉ុន្តែទំនងជាប្រជាពលរដ្ឋខ្មែរមានកំហឹងដល់កទប់ពុំបាន ព្រោះខ្លះបានលក់គោលក់ក្របីលក់របស់របរផ្សេងៗ ខ្លះខ្ចីប្រាក់គេដោយខ្លួនជាអ្នកក្រីក្រ បានប្រាក់សំរាប់ចំណាយក្នុងការធ្វើដំណើរពីស្រុកស្រែចំការមកក្រុងភ្នំពេញ ដើម្បីស្តាប់អាចារ្យគ្រិស្តក្រែងខ្លួនបានជារោគបានជាពីពិការ តែពុំបាន

សំរេចដូចបំណង ឯប្រាក់ដ៏អស់ ក៏កើតការក្តៅក្រហាយនេះឡើង ណាមួយក្តៅក្រហាយនឹងអាជ្ញាធរខ្មែរពុករលួយឲ្យច្បាប់ឲ្យអាចារ្យគ្រិស្តនេះនិយាយបោកប្រាស់ប្រជាពលរដ្ឋរបស់ខ្លួន ធ្វើឲ្យប្រជាពលរដ្ឋដែលក្រីក្រស្រាប់ហើយនោះខាតបង់ទ្រព្យសម្បត្តិថែមទៀត។ ភ័ស្តុតាងក្នុងពេលនោះមួយទៀត គឺមានបុរសម្នាក់ដែលមានភ្នែកភ្លឺ ប៉ុន្តែគេជួលឲ្យក្លែងធ្វើជាខ្វាក់ ដើម្បីឲ្យអាចារ្យគ្រិស្តធ្វើជាវេជ្ជបណ្ឌិតមើលភ្នែកដែលជាឲ្យជាដដែល។ ប្រជាពលរដ្ឋខ្មែរបានដឹងការពិតអំពីការបោកប្រាស់នេះហើយ ទើបកើតការប្រឆាំងនេះឡើង។ នៅសម័យអាណានិគមបារាំងជិតមួយសតវត្សរ៍ បារាំងបានខំពន្យល់អូសទាញប្រជាពលរដ្ឋខ្មែរឲ្យចូលកាន់សាសនាគ្រិស្ត ប៉ុន្តែលទ្ធផលជាអវិជ្ជមាន គឺប្រជាពលរដ្ឋពុំចូលកាន់សាសនាគ្រិស្តឡើយ បើមានក៏មានចំនួនតិចបំផុត។ បេសកជនសាសនាគ្រិស្តបញ្ចុះបញ្ចូលបានតែជនជាតិខ្លះដែលស្ថិតនៅប្រទេសក្រីក្រនិងប្រទេសដែលមានវិបត្តិនយោបាយនៅទ្វីបអាស៊ី អាហ្វ្រិក និងអាមេរិកឡាទីន តាមរយៈការផ្តល់អំណោយមានចំណង។ បេសកជនសាសនាគ្រិស្តជាជាតិខ្មែរដែលចេញពីបរទេសទៅខំឃោសនាអួតក្អេងក្អាងថា ពី១០ទៅ២០ឆ្នាំ នឹងធ្វើឲ្យប្រទេសខ្មែរទៅជាប្រទេសកាន់គ្រិស្តសាសនាទាំងអស់។ ពួកវង្វេងបឹងទាំងនោះ មិនត្រឹមតែលើកដម្កើងសាសនារបស់ខ្លួន ហើយបញ្ចុះបញ្ចូលឲ្យពុទ្ធសាស

និកជនខ្មែរចូលកាន់គ្រិស្តសាសនាប៉ុណ្ណោះទេ ថែមទាំងពោលប្រមាថតិះដៀលព្រះពុទ្ធសាសនានិងព្រះសង្ឃជាទីគោរពរបស់ពុទ្ធសាសនិកជនខ្មែរថែមទៀតផង។ ដូចជាមានកន្លែងខ្លះគេបង្ខំឲ្យជនជាតិខ្មែរដែលជឿគ្រិស្តសាសនាឲ្យជាន់ព្រះពុទ្ធរូបទើបគេជឿថា ជឿគ្រិស្តសាសនាពិតមែន។

តាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ការជួយសង្គ្រោះមនុស្សសត្វត្រូវធ្វើឡើងប្រកបដោយមេត្តាធម៌ ដោយទឹកចិត្តបរិសុទ្ធ ពុំមានលក្ខខណ្ឌ គឺមិនចង់បានប្រយោជន៍អ្វីពីអ្នកដែលខ្លួនជួយនោះវិញឡើយ។ បើការជួយនោះព្រោះតែចង់ទាញយកផលប្រយោជន៍អ្វីមួយមកវិញនោះ ពុំឈ្មោះថាជួយប្រកបដោយករុណាធម៌ក្នុងនាមសង្គហធម៌តាមឧត្តមគតិព្រះពុទ្ធសាសនាឡើយ។ យ៉ាងណាមិញ ក្រុមផ្សាយសាសនាគ្រិស្ត គួរតែធ្វើខ្លួនឲ្យថ្លៃថ្នូរជាជនមានអរិយធម៌ខ្ពស់ក្នុងនាមសាសនាគ្រិស្ត មិនគួរប្រើមធ្យោបាយបោកប្រាសប្រជាពលរដ្ឋខ្មែរ ដែលនៅទន់ខ្សោយដោយប្រាជ្ញាស្មារតីបែបនេះឡើយ។ សូមពិចារណាគ្រឿងឧបមាមួយថា អ្នកស្ទូចត្រីបោះសន្ទូចទៅក្នុងទឹក ពេលត្រីស៊ីនុយត្រីជាប់ងៀងសន្ទូច គេក៏វាត់សន្ទូចឡើងសម្លាប់ត្រីយកមកធ្វើម្ហូប។ តើអ្នកស្ទូចត្រីដែលដាក់នុយត្រង់ងៀងសន្ទូចឲ្យត្រីវាស៊ីនោះ តើអ្នកនោះមានធម៌សប្បុរសធ្វើទានដល់ត្រី ឬជាការបញ្ឆោតត្រីឲ្យត្រីវាស៊ីជាប់ងៀងសន្ទូច ហើយវាត់ឡើងសម្លាប់ត្រីយកត្រីមកធ្វើ

មួបទេ។ ជាការពិតណាស់ ក្រុមផ្សាយសាសនាគ្រិស្តដែល ចែកអំណោយដល់ខ្មែរ ហើយបង្ខំឲ្យគេជឿសាសនាខ្លួនមាន លក្ខណៈដូចគ្នានឹងអ្នកស្នួចត្រីនេះដែរ។ ដូច្នេះ គេអាចទាញ ផលវិបាកមកថា អ្នកផ្សាយសាសនាគ្រិស្តកំពុងតែធ្វើសកម្ម ភាពសម្លាប់វប្បធម៌ដែលជាព្រលឹងរបស់ខ្មែរ គឺព្រះពុទ្ធសាស នាយ៉ាងពិតប្រាកដណាស់។ ក្រុមផ្សាយសាសនាគ្រិស្តត្រូវ តែបញ្ឈប់សកម្មភាពរំលោភសិទ្ធិមនុស្សបែបនេះ ហើយបែរ មកបំពេញសកម្មភាពមនុស្សធម៌ឲ្យត្រឹមត្រូវ ដូចអង្គការមនុស្ស ធម៌នានានៅប្រទេសកម្ពុជា។ បើអាណិតអាសូរប្រជាពលរដ្ឋ ខ្មែរ សូមទុកឲ្យកូនចៅខ្មែររក្សាជំនឿដើមរបស់ពួកគេ គឺព្រះ ពុទ្ធសាសនាដែលសព្វថ្ងៃនេះមាន៩៥%។ គួរយកតម្រាប់តាម តារាភាពយន្តហូលីវូត គឺនាងអន់ជូលីណា ជូលីដែលបានសុំ កូនកំព្រាខ្មែរម្នាក់មកចិញ្ចឹម។ កូនប្រុសនេះមានអាយុ៧ឆ្នាំ នៅឆ្នាំ២០០៨នេះ។ នាងឲ្យកូនប្រុសនោះរក្សាវប្បធម៌ដើម គឺព្រះពុទ្ធសាសនាដោយបានជាវព្រះពុទ្ធរូបមួយអង្គពីកម្ពុជា ឲ្យកូនចិញ្ចឹមនោះថ្វាយបង្គំរាល់ពេល។ ចំពោះពុទ្ធសាសនិក ជនខ្មែរនៅបរទេសដែលបង្កើតវត្តអារាមគ្រប់ទីកន្លែងនោះ គ្មានបំណងផ្សាយសាសនារបស់ខ្លួនទៅជនបរទេសឡើយ គឺគ្រាន់តែរក្សាវប្បធម៌ទំនៀមទម្លាប់ព្រះពុទ្ធសាសនារបស់ ខ្លួន ដែលធ្លាប់ប្រតិបត្តិមកឲ្យគង់វង់ប៉ុណ្ណោះ ប៉ុន្តែបើមានគេ ចង់ដឹង មានចិត្តរីករាយពន្យល់គេ ហើយគ្មានបំណងទាក់

ទាញឲ្យគេជឿឡើយ។ ព្រះពុទ្ធខ្លួនព្រះអង្គបានពោលថា តថាគតទេសនាពន្យល់ធម៌ដល់អ្នករាល់គ្នា ប៉ុន្តែមុននឹងជឿតថាគត ចូរអ្នកពិចារណាឲ្យយល់ដោយខ្លួនឯងជាមុនសិន។ ដូច្នេះ ព្រះពុទ្ធសាសនាជាសាសនាពុំបង្ខំគេឲ្យជឿឡើយ តែជាសាសនាទុកសិទ្ធិឲ្យគេសំរេចចិត្តជឿឬពុំជឿដោយខ្លួនគេ។

ចំពោះរាជរដ្ឋាភិបាលខ្មែរបច្ចុប្បន្ន ការបើកសិទ្ធិខាងជំនឿជាការត្រឹមត្រូវហើយតាមច្បាប់អន្តរជាតិចំពោះប្រជាពលរដ្ឋខ្មែរដែលរស់នៅប្រទេសកម្ពុជាជាមាតុភូមិរបស់ខ្លួន ប៉ុន្តែបើមានជនបរទេសមកផ្សាយសាសនាគេនៅប្រទេសកម្ពុជា ត្រូវស្ថិតនៅក្រោមច្បាប់មួយទៀតសំរាប់ប្រទេសខ្មែរដែលជាប្រទេសទុកព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋដែលរដ្ឋាភិបាលត្រូវឧបត្ថម្ភ និងរក្សាការពារជំនឿរបស់ប្រជាពលរដ្ឋខ្មែរ។ ហួសពីនាទីរបស់ខ្លួន មានអង្គការមនុស្សធម៌ខ្លះ ពេលសុំច្បាប់ ប្រាប់អាជ្ញាធរខ្មែរថា ខ្លួនមកជួយប្រជាពលរដ្ឋខ្មែរក្នុងនាមមនុស្សធម៌ ប៉ុន្តែនេះគ្រាន់តែជាផ្លាកខាងក្រៅ ភាពពិតខាងក្នុង គឺការផ្សាយសាសនាគ្រិស្ត រហូតទាក់ទាញយុវវ័យខ្មែរដែលជាវ័យនៅទន់ខ្សោយខាងប្រាជ្ញាស្មារតីឲ្យបោះបង់ព្រះពុទ្ធសាសនា ហើយកាន់គ្រិស្តសាសនាវិញថែមទាំងរិះគន់ព្រះសង្ឃព្រះពុទ្ធសាសនាដែលជាស្ថាប័នដ៏ធំរបស់ប្រទេសកម្ពុជា និងមិនឲ្យដឹងគុណមាតាបិតាដែលជា

មូលដ្ឋានវប្បធម៌ខ្មែរផង។ នេះជាភារកិច្ចរបស់រាជរដ្ឋាភិបាលខ្មែរដែលទទួលខុសត្រូវចំពោះវាសនាជាតិដែលមាននាទីការពារព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ដែលជាបារចនារបស់ជាតិមានចែងក្នុងធម្មនុញ្ញខ្មែរបច្ចុប្បន្ន ត្រូវចាត់វិធានការបែបណាចំពោះអង្គការមនុស្សធម៌ខ្លះដែលធ្វើការហួសព្រំដែនរបស់ខ្លួន រំលោភច្បាប់ខ្មែរបែបនេះ។ គេសង្កេតឃើញការិយាល័យគ្រិស្តសាសនាមានស្ទើរតែគ្រប់កន្លែងនៅពាសពេញប្រទេសកម្ពុជា រហូតចុងកាត់មាត់ញកជនបទក៏មានដែរ នេះដោយសារអំពើពុករលួយរបស់អាជ្ញាធរខ្មែរចង់បានដុល្លារផ្ទាល់ខ្លួន និងចង់ចំណេញខាងផ្លូវនយោបាយដោយពុំគិតពីគំនិតជាតិនិយមរបស់ខ្លួន និងពុំគិតពីគ្រោះថ្នាក់ទៅអនាគតដែលអាចកើតសង្គ្រាមសាសនា។ ប៉ុន្តែស្មារតីដ៏ខ្ពង់ខ្ពស់របស់ប្រជាពលរដ្ឋខ្មែរចំពោះព្រះពុទ្ធសាសនាដែលជាព្រលឹងរបស់ខ្លួនមានភាពរឹងមាំពុំរង្គោះរង្គើឡើយ គឺពុំព្រមលក់ឧត្តមគតិឲ្យអ្នកណាទាំងអស់។ បានសេចក្ដីថា គេឲ្យអំណោយទទួលយក ប៉ុន្តែរឿងមិនជឿគឺជាសិទ្ធិរបស់ខ្លួនជាប្រជាពលរដ្ឋខ្មែរឯករាជ្យ ចំពោះអំណោយដែលមានបង្កប់ពាក្យឃោសនានៅក្នុងនោះ។ ក្រុមផ្សាយសាសនាគ្រិស្តកុំយល់សប្តិថា ខ្លួនអាចធ្វើឲ្យប្រទេសកម្ពុជាដែលគោរពព្រះពុទ្ធសាសនាស្ទើរតែ១០០% ក្លាយជាប្រទេសកាន់គ្រិស្តសាសនាតាមការឃោសនារបស់ខ្លួនឡើយ ព្រោះប្រជាពល

រដ្ឋខ្មែរសុខចិត្តក្រមិនលក់ឧត្តមគតិខាងជំនឿនេះឲ្យជនណាឡើយ។ ភស្តុតាងឃើញស្រាប់ហើយ ពួកឃាតករខ្មែរក្រហមបានព្យាយាមរំលាយព្រះពុទ្ធសាសនាឲ្យដល់ឫសគល់ ឥឡូវនេះពុទ្ធសាសនាជាសច្ចធម៌ពុំស្លាប់នៅរស់ដដែល ហើយពួកបំផ្លាញព្រះពុទ្ធសាសនាត្រូវវិនាសខ្លួនឯង។ ដរាបណានៅមានខ្មែរ ដរាបនោះនៅមានព្រះពុទ្ធសាសនា ព្រោះព្រះពុទ្ធសាសនាបានរលាយជាសាច់ជាឈាមនៅក្នុងខ្លួនរបស់ពួកគេអស់ទៅហើយ។ ដូច្នេះគ្រិស្តសាសនាកុំសាកល្បងដើរតួតំណាងឲ្យពួកកុម្មុយនិស្តខ្មែរក្រហមបន្តមកទៀត ពិតជាពុំបានជោគជ័យឡើយ។ ជឿព្រះពុទ្ធសាសនាគឺជឿការពិតដែលព្រះអង្គបានសំដែង ហើយយកពាក្យនោះមកពិចារណានិងអនុវត្តក្នុងជីវភាពប្រចាំថ្ងៃ ឃើញសច្ចធម៌ពិតមែនពុំអាចប្រែក្រឡះពីញាណទស្សនៈ ឃើញការពិតនេះ ទៅជឿអ្វីដែលពុំមានការពិតនោះឡើយ។ ចំពោះសាសនាឥស្លាមនៅប្រទេសកម្ពុជាសព្វថ្ងៃ មានវិហារឥស្លាមទាំងធំទាំងតូចមានច្រើនណាស់។ ការលូតលាស់រហ័សនេះដោយការឧបត្ថម្ភពីប្រទេសកាន់សាសនាឥស្លាមក្រៅប្រទេស។ការសិក្សាពីសាសនាឥស្លាមរបស់ឥស្លាមសានិកមិនជាអ្វីទេ ប៉ុន្តែមតិទូទៅមានការព្រួយបារម្ភនោះ គឺក្រែងពួកភេរវជនយកសាសនាឥស្លាមជាបង្អែកសំរាប់សិក្សាអំពីល្បិចនិងការអនុវត្តភេរវកម្ម ដែលពេលថ្មីៗនេះតំណាងអង្គការសហប្រជាជាតិបានថ្លែងថា

កម្ពុជាអាចជាជំរកសុខសាន្តរបស់ក្រុមភេរវជន។ សព្វថ្ងៃនេះ រាជរដ្ឋាភិបាលខ្មែរក៏យកចិត្តទុកដាក់បានបង្កើតច្បាប់សំរាប់ផ្តន្ទាទោសពួកភេរវជនផងដែរ។

## ៤- អំណោយរបស់សាសនាគ្រិស្ត ជាអាវុធសម្លាប់ពុទ្ធសាសនាខ្មែរ

សាសនាគ្រិស្តមានគោលបំណងទាក់ទាញពុទ្ធសាសនិកជនខ្មែរឲ្យជឿសាសនាសរបស់ខ្លួននៅពេលដែលពុទ្ធសាសនិកជនខ្មែរកំពុងស្ថិតនៅក្នុងភាពក្រីក្រនិងទន់ខ្សោយខាងបញ្ញាស្មារតី។ ដើម្បីសម្រេចបំណងនេះ សាសនានេះបានប្រើមធ្យោបាយផ្តល់អំណោយនិងមធ្យោបាយបង្រៀនភាសាបរទេសមួយដែលកំពុងពេញនិយមនៅប្រទេសកម្ពុជា គឺភាសាអង់គ្លេសដោយឥតគិតថ្លៃ។ ជំនួយមានចំណងបែបនេះផ្ទុយពីទានក្នុងព្រះពុទ្ធសាសនា ព្រោះទានក្នុងព្រះពុទ្ធសាសនាប្រកបដោយចេតនាល្អ គឺការលះបង់សេចក្តីកំណាញ់ផ្លូវចិត្ត ឲ្យដោយចិត្តបរិសុទ្ធគ្មានចង់បានអ្វីពីអ្នកដែលខ្លួនឲ្យនោះឡើយ។ ចំពោះអំណោយដែលសាសនានោះបានផ្តល់ឲ្យដល់ពុទ្ធបរិស័ទខ្មែរទុកជាផ្លាក់សំរាប់ទាក់ទាញជនជាតិខ្មែរឲ្យចូលកាន់សាសនារបស់ខ្លួន ដោយឲ្យលះបង់ព្រះពុទ្ធសាសនាដែលជនជាតិខ្មែរច្រើនលើសលប់បានគោរពនិងកំពុងកាន់សព្វថ្ងៃនេះ។ និយាយម៉្យាងទៀត អំណោយរបស់សាសនានោះ ប្រៀបប្រដូចជានុយសន្ទូចដែលគេដាក់ត្រង់ផ្លៀងសន្ទូចដើម្បីបញ្ឆោតត្រីឲ្យមកស៊ីរួចគេវាត់ឡើងសម្លាប់ត្រីធ្វើម្ហូប។ យ៉ាងណាមិញ ការយកអំណោយ

បន្តិចបន្តួចមកចែកឲ្យប្រជាពលរដ្ឋខ្មែរ ទុកជាអាវុធសំរាប់សម្លាប់ព្រះពុទ្ធសាសនាខ្មែរ។ ប្រជាពលរដ្ឋខ្មែរខ្លះបានទទួលយកអំណោយនោះ តែនៅតែរក្សានូវឧត្តមគតិរបស់ខ្លួនដដែល គឺព្រះពុទ្ធសាសនា។ សាសនានោះបានប្រើវិធីដូចគ្នានេះទៅលើជនជាតិភាគតិចនៅខេត្តមណ្ឌលគិរី និងរតនគិរី រហូតដល់កុមារាកុមារីខ្មែរ ដែលជាវ័យពុំទាន់ចេះពិចារណារកការពិតនៅឡើយឲ្យជឿសាសនារបស់ខ្លួន។ ទោះបីអំពើនេះគេដឹងថាជាការរំលោភសិទ្ធិមនុស្ស ដូចជាគេបង្ខំក្មេងពុំទាន់ពេញវ័យឲ្យជឿជាដើម ក៏គេពុំកោតញញើតអ្វីឡើយ ព្រោះច្បាប់ខ្មែរតុលាការខ្មែរធូរនិងពុករលួយ។ នេះជាការប្រមាថមើលងាយរាជរដ្ឋាភិបាល និងប្រជាពលរដ្ឋខ្មែរ។ ការផ្តល់អំណោយដែលខាងក្នុងបង្កប់ដោយពិសពុលនេះជាការសម្លាប់វប្បធម៌ខ្មែរ គឺព្រះពុទ្ធសាសនា។ អំណោយទានឲ្យរស់ផ្លូវកាយ ប៉ុន្តែសម្លាប់មនោសញ្ចេតនាផ្លូវចិត្ត។ ឯអំណោយនោះទៀតពុំមែនឲ្យរហូតទេ គ្រាន់តែចេះរៀបចំផ្ទេរពីអ្នកចាស់មកអ្នកថ្មី ពេលអ្នកចូលថ្មីនោះរឹងដៃរឹងជើង គេទាវវិភាគទានឲ្យអ្នកថ្មីៗជាបន្តទៅទៀត។ជូនកាលអំណោយទានខ្លះដែលអែអង្គាសពីបរទេសថាយកមកជួយប្រជាពលរដ្ឋខ្មែរជាផ្លូវមនុស្សធម៌ តែបែរជាយកមកសម្លាប់វប្បធម៌ខ្មែរទៅវិញ។ នេះឯងហើយដែលគេថា បើជឿសាសនាគេទៅ បងប្អូននឹងទទួលអំណោយឧបត្ថម្ភ ចំណែកព្រះសង្ឃព្រះពុទ្ធ

សាសនាគ្មានបានផ្តល់អ្វីជូនបងប្អូនទេ មានតែយកពីបងប្អូន ទៅវិញ។

ចំពោះព្រះសង្ឃព្រះពុទ្ធសាសនាដែលមានសីលបរិ-សុទ្ធ ត្រូវបានទទួលមតិកគឺបច្ច័យ៤ ដែលពុទ្ធបរិស័ទប្រគេន ដោយសទ្ធាជ្រះថ្លា មតិកនោះ បាលីហៅថាទាយជ្ជបរិភោគ។ តើពុទ្ធបរិស័ទដែលប្រគេននោះបានផលប្រយោជន៍អ្វីខ្លះ? ហើយព្រះសង្ឃបានផ្តល់ជូនពុទ្ធបរិស័ទវិញយ៉ាងណាខ្លះ? ធម្មតាចិត្តរបស់មនុស្សបុថុជ្ជន តែងប្រឡាក់ប្រឡូសដោយ គ្រឿងសៅហ្មងមានលោភៈទោសៈមោហៈជាដើម។ ព្រះពុទ្ធ សំដែងថា លះលោភៈដោយការធ្វើទាន លះទោសៈដោយ ការរក្សាសីល លះមោហៈដោយសមាធិនិងវិបស្សនា។ ហេតុ ដែលព្រះពុទ្ធបង្រៀនឲ្យមនុស្សលះអកុសលទាំងបីនេះ ព្រោះវានាំឲ្យមនុស្សសាងបាបកម្ម។ ដូច្នេះ យើងឃើញថា ការលះលោភៈដោយការធ្វើទាន។ យ៉ាងណាមិញ ការធ្វើទាន ចំពោះព្រះសង្ឃរបស់ពុទ្ធបរិស័ទខ្មែរដើម្បីលះលោភចិត្ត ព្រោះព្រះសង្ឃជាអ្នកមានគុណធម៌មានសីលគុណជាដើម ដែលអាចទាញទឹកចិត្តរបស់ពុទ្ធបរិស័ទខ្មែរឲ្យលះបង់មច្ឆរិយ ចិត្តនិងលោភចិត្ត ដែលជាអកុសលមានកម្រឹតខ្ពស់។ ដូច្នេះ បច្ច័យ៤មានចីវរបច្ច័យជាដើម ដែលប្រគេនព្រះសង្ឃទុកជា ឱសថសំរាប់ដុះខាត់គ្រឿងមន្ទិលគឺលោភៈចេញពីចិត្ត។ ប្រៀបដូចសាប៊ូសំរាប់យកមកដុសសំអាតរាងកាយឲ្យស្អាត។

បច្ច័យ៤ជាហេតុ បដិគ្គាហកៈគឺព្រះសង្ឃជាហេតុ ដែលនាំឲ្យចិត្តលះអកុសលគឺលោភៈនេះជាផល។ បុញ្ញក្ខេត្ត ប្រែថាព្រះសង្ឃជាស្រែបុណ្យ ព្រោះព្រះសង្ឃជាអ្នកមានគុណធម៌មានសីលគុណជាដើម ដែលពុទ្ធបរិស័ទបូជាទានរមែងបានផលអានិសង្សច្រើន ប្រៀបដូចស្រែមានជីរជាតិដែលធ្វើឲ្យដំណាំដុះលូតលាស់ល្អ។ ពុទ្ធបរិស័ទដែលប្រគេនបច្ច័យ៤ចំពោះព្រះសង្ឃដោយចិត្តជ្រះថ្លាដ៏បរិសុទ្ធ លះទេយ្យវត្ថុធ្វើទានដោយដាច់ខាតគ្មានចង់បានអ្វីពីព្រះសង្ឃវិញឡើយ។

តើព្រះសង្ឃផ្ដល់អ្វីវិញដល់ពុទ្ធបរិស័ទ?

ពុទ្ធបរិស័ទខ្មែរបានប្រគេនបច្ច័យ៤ចំពោះព្រះសង្ឃជាអាមិសទាន ចំណែកព្រះសង្ឃវិញបានធ្វើទានចំពោះពុទ្ធបរិស័ទវិញហៅថាធម្មទាន ប្រែថាទានធម៌ គឺការសំដែងធម៌ទេសនាពន្យល់ពុទ្ធបរិស័ទអំពីបាបបុណ្យគុណទោសបង្ហាញហេតុដែលគួរធ្វើហេតុដែលពុំគួរធ្វើ ហេតុដែលនាំឲ្យមានសេចក្ដីចំរើន ហេតុដែលនាំឲ្យមានសេចក្ដីវិនាសជាដើម។ ការពន្យល់ប្រាប់មធ្យោបាយល្អមធ្យោបាយត្រូវដើម្បីឲ្យអ្នកស្ដាប់យកទៅអនុវត្តដើម្បីសេចក្ដីសុខចំរើនជាការប្រសើរជាងការឲ្យអ្វីទាំងអស់ ដូចពុទ្ធភាសិតថា សព្វទានំ ធម្មទានំ ជិនាតិ ប្រែថា ធម្មទានឈ្នះទានទាំងពួង។ បានសេចក្ដីថា ការប្រាប់មធ្យោបាយហេតុដែលនាំឲ្យបានសុខ

ចំរើនដែលហៅថាធម្មទានរមែងប្រសើរជាងការឲ្យទាំងពួង ដែលហៅថា អាមិសទាន។ ប្រៀបដូចការឲ្យផ្លែស្វាយមួយ គេបរិភោគតែ១ពេលក៏អស់ទៅ ប៉ុន្តែបើគេមិនឲ្យផ្លែស្វាយទេ គេឲ្យគ្រាប់ស្វាយយកទៅដាំ ហើយប្រាប់មធ្យោបាយដាំឲ្យ មានផ្លែច្រើន លុះស្វាយដុះឡើងជាដើមបែកមែកចេញជាផ្លែ គេបេះរាល់ឆ្នាំ។ ដូច្នេះការប្រាប់មធ្យោបាយដែលហៅថា ធម្មទាន ប្រសើរជាងការឲ្យវត្ថុផ្សេងៗដែលហៅថាអាមិស ទាន។ ពុទ្ធបរិស័ទដែលអាចប្រតិបត្តិត្រឹមត្រូវតាមព្រះពុទ្ធ សាសនាក៏ដោយសារបានស្តាប់ព្រះសង្ឃពន្យល់ប្រាប់តាម រយៈធម៌ទេសនា និងការបង្ហាត់បង្រៀន។ បើនិយាយតាមផ្លូវ អាណាចក្រ ព្រះសង្ឃទុកដូចគ្រូបង្រៀន ពុទ្ធបរិស័ទទុកជា កូនសិស្ស ឯការប្រគេនបច្ច័យ៤ដល់ព្រះសង្ឃទុកដូចជាការ ប្រគេនប្រាក់ខែដល់ព្រះសង្ឃ។ តាមពិត ព្រះសង្ឃទេសនា ពន្យល់ពុទ្ធបរិស័ទដោយករុណាចិត្ត គ្មានចង់បានអ្វីពីពុទ្ធបរិ ស័ទឡើយ ចំណែកពុទ្ធបរិស័ទបានប្រគេនបច្ច័យ៤ដល់ព្រះ សង្ឃដោយសទ្ធាជ្រះថ្លា គ្មានការបង្ខិតបង្ខំឡើយ។ សេចក្តី សុខចំរើនគ្រប់យ៉ាងស្ថិតនៅលើផ្លូវចិត្ត ដែលមានធម៌សន្តោស ធម៌មេត្តាប្រកបដោយបញ្ញាស្មារតីចេះវិនិច្ឆ័យត្រឹមត្រូវតាម ហេតុការណ៍ក្នុងដំណោះស្រាយបញ្ហាជីវិត ឯសម្ភារៈគ្រាន់ តែជាគ្រឿងផ្សំប៉ុណ្ណោះ។ ព្រះសង្ឃណែនាំពុទ្ធបរិស័ទឲ្យចេះ រស់នៅក្នុងជីវិតស្ងប់មិនប្រើធម៌ហឹង្សា មានមេត្តាករុណាចំ

ពោះខ្លួនឯង ចំពោះអ្នកនៅជុំវិញខ្លួននិងមនុស្សទូទៅ។ ក្រៅពីផ្នែកវប្បធម៌ ព្រះសង្ឃបានជួយផ្នែកសង្គមកិច្ចរហូតព្រះអង្គបានដឹកនាំដោយផ្ទាល់ខ្លួនក្នុងការកសាងសាលារៀន មន្ទីរពេទ្យ ផ្លូវថ្នល់ជាដើម។ ព្រះសង្ឃបានសង្គ្រោះនិងអប់រំកុមារខ្មែរដែលឥតទីពឹង ឲ្យមកស្នាក់នៅក្នុងវត្តឲ្យមានចំណេះចេះដឹងនិងសីលធម៌ ឲ្យក្លាយទៅជាពលរដ្ឋដ៏ល្អរបស់សង្គម។ ក្រៅពីនោះ បើទេយ្យវត្ថុគេប្រគេនច្រើន ព្រះសង្ឃតែងយកទេយ្យវត្ថុទាំងនោះទៅចែកជូនអ្នកក្រីក្រកំសត់ទុរគតទៀតផង។ ឱកាសខ្លះ ពេលមានភាពអាសន្នដូចជាទឹកលិច ខ្យល់ព្យុះ ទុរភិក្សអត់បាយ ព្រះសង្ឃដើររៃអង្គាសប្រាក់កាស និងសម្ភារៈយកទៅជួយអ្នកទទួលរងគ្រោះពីបាតុភូតធម្មជាតិទាំងនោះ ដោយករុណាចិត្ត គឺការអាណិតអាសូរ។ ដូច្នេះបញ្ជាក់ថា ព្រះសង្ឃមិនត្រឹមតែធ្វើធម្មទានប្រាប់មធ្យោបាយល្អក្នុងបញ្ហាជីវិតឲ្យរស់នៅសុខស្រួលក្នុងសង្គម និងការរំលត់ទុក្ខក្នុងព្រះនិព្វានប៉ុណ្ណោះទេ សូម្បីវត្ថុសម្ភារៈក៏ព្រះសង្ឃជួយផ្តល់ដល់ពុទ្ធបរិស័ទដែរ ស្របទៅតាមពេលវេលា និងទៅតាមលទ្ធភាព។

ដូចបានពោលមកហើយ ចម្លើយឆ្លើយតបទៅសាសនាមួយដែលគេឃោសនាថា សាសនាគេជួយបរិស័ទ ចំណែកព្រះសង្ឃព្រះពុទ្ធសាសនាយកវត្ថុពីពុទ្ធបរិស័ទវិញ។ តាមពិត វត្ថុដែលសាសនានោះជួយជាថ្នាំពិសពុលសំរាប់

សម្លាប់ព្រះពុទ្ធសាសនាខ្មែរដែលជាអត្តសញ្ញាណជាតិ។ ចំណែកព្រះសង្ឃដែលទទួលទេយ្យវត្ថុពីពុទ្ធបរិស័ទសំរាប់ឧបត្ថម្ភឲ្យព្រះសង្ឃរស់នៅ ដើម្បីបំពេញកិច្ចការក្នុងព្រះពុទ្ធសាសនាខាងផ្នែកពុទ្ធចក្រនិងជួយពង្រឹងខាងផ្នែកអាណាចក្រឲ្យដើរទៅទន្ទឹមគ្នា ដើម្បីសេចក្ដីសុខសាន្តនៃប្រទេសកម្ពុជាមាតុភូមិ។ សាសនានោះភ្លេចខ្លួនថា វត្ថុផ្សេងៗដែលសាសនានោះមានតើបានមកពីណា? មិនបានមកពីបរិស័ទរបស់ខ្លួនដូចតែគ្នាទេឬ? ពុំមែនកើតមកពីព្រះជាម្ចាស់ផ្ដល់ឡើយ។ ដូច្នេះពុទ្ធបរិស័ទខ្មែរក្នុងប្រទេសនិងក្រៅប្រទេសត្រូវពង្រឹងជំហរក្នុងព្រះពុទ្ធសាសនាឲ្យបានរឹងមាំថែមទៀត កុំជឿការឃោសនាគ្មានសច្ចភាពរបស់សាសនានេះឡើយ។

## ៥- ជួយខ្មែរឲ្យរស់តាមផ្លូវកាយ ប៉ុន្តែសម្លាប់វប្បធម៌ខ្មែរតាមផ្លូវចិត្ត

អង្គការគ្រិស្តសាសនា បើមានបំណងល្អជួយពលរដ្ឋខ្មែរ សូមកុំប៉ះពាល់ដល់វប្បធម៌ព្រះពុទ្ធសាសនាខ្មែរ ទុកឲ្យខ្មែររក្សាវប្បធម៌របស់ខ្លួនដូចដើម។ ការផ្តល់អំណោយបន្តិចបន្តួចឲ្យរស់ផ្លូវកាយ ប៉ុន្តែសម្លាប់ផ្លូវចិត្ត នេះជាអំពើបាប។ ការធ្វើទានតាមផ្លូវព្រះពុទ្ធសាសនា គឺការលះមច្ឆរិយៈដែលជាតួលោភៈផ្លូវចិត្ត ប្រកបដោយចិត្តបរិសុទ្ធ គ្មានចង់បានអ្វីមកវិញឡើយ។ បើឲ្យវត្ថុអ្វីមួយដោយចង់បានអ្វីមួយមកវិញ ពុំឈ្មោះថាឲ្យឡើយ ឈ្មោះថាដូរគ្នា។ បើឲ្យវត្ថុអ្វីមួយចង់ឲ្យគេជួយអ្វីមួយត្រឡប់វិញ ក៏មិនឈ្មោះថាឲ្យឡើយ ឈ្មោះថាឲ្យថ្លៃឈ្នួល។ តាមន័យនេះ ការផ្តល់អំណោយ ការជួយបង្រៀនភាសាអង់គ្លេសជាដើមរបស់អ្នកផ្សាយសានាគ្រិស្តដល់ពលរដ្ឋខ្មែរ មានគំនិតអាក្រក់បំផុត ព្រោះអំណោយនេះជានុយបញ្ឆោតឲ្យពលរដ្ឋខ្មែរ ជាពិសេសយុវជនខ្មែរឲ្យជឿមនោគមវិជ្ជាសាសនាគ្រិស្ត ហើយសម្លាប់វប្បធម៌ពុទ្ធសាសនាខ្មែរ។ ជាការលោភសិទ្ធិមនុស្សរបស់សាសនាគ្រិស្តមកលើពលរដ្ឋខ្មែរ ព្រោះពុំមែនខ្មែររត់ទៅចូលសាសនាគ្រិស្តទេ គឺសាសនាគ្រិស្តទៅបញ្ចុះបញ្ចូលលួងលោមបោកបញ្ឆោតឲ្យជឿ ជាពិសេសចំពោះយុវជនខ្មែរដែលជាអនីតិជន ជាវ័យមិនទាន់ទទួលខុសត្រូវតាមផ្លូវច្បាប់ មិនទាន់ចេះពិចារណា។ ដូចនេះ

២៩

ភ្នាក់ងារសាសនាគ្រិស្តត្រូវតែបញ្ឈប់នូវអំពើរំលោភសិទ្ធិមនុស្សរបស់ខ្លួន ក្នុងការទាក់ទាញកូនក្មេងឲ្យជឿ ប្រយ័ត្នម្តាយឪពុកគេប្តឹងឡើងតុលាការកាត់ទោស។

## ៦- អ្នកផ្សាយគ្រិស្តសាសនាខ្មែរថា ព្រះយេស៊ូជាព្រះសិអារ្យមេត្រី

សេចក្តីពិត ក្នុងគម្ពីរនៃសាសនានេះមិនមាននិយាយអំពីព្រះសិអារ្យមេត្រីនេះទេ ប៉ុន្តែអ្នកផ្សាយគ្រិស្តសាសនាខ្មែរបាននិយាយបន្លំ ដោយយកព្រះសិអារ្យក្នុងព្រះពុទ្ធសាសនា ថាជាព្រះយេស៊ូ ដើម្បីបញ្ឆោតខ្មែរឲ្យជឿព្រះយេស៊ូ។ ពេលនេះ យើងសូមអធិប្បាយអំពីព្រះសិអារ្យមេត្រីរបស់ព្រះពុទ្ធសាសនា។ ក្នុងព្រះពុទ្ធសាសនានិយាយថា សុញ្ញកប្ប ប្រែថាកប្បសូន្យ គឺកប្បគ្មានព្រះពុទ្ធសត្រាស់ដឹង អសុញ្ញ - កប្ប ប្រែថា កប្បមិនសូន្យគឺកប្បមានព្រះពុទ្ធត្រាស់ដឹង។ កប្បដែលមានព្រះពុទ្ធត្រាស់ដឹងមានចំនួនព្រះពុទ្ធត្រាស់ដឹងពុំស្មើគ្នាទេ។ ចំពោះកប្បបច្ចុប្បន្ននេះ ហៅថា ភទ្ទកប្ប ប្រែថាកប្បចំរើនមានព្រះពុទ្ធត្រាសដឹង៥ព្រះអង្គគឺ ព្រះពុទ្ធព្រះនាម កក្កុសន្ធោ កោនាគមនោ កស្សបោ គោត្តមោ និងព្រះអរិយមេត្តេយ្យ ឬព្រះសិអារ្យមេត្រី។ កប្បមានព្រះពុទ្ធត្រាស់ដឹងមួយអង្គហៅថាសារកប្ប ត្រាស់ពីរអង្គហៅថាមណ្ឌកប្ប ត្រាស់បីអង្គហៅថាវរកប្ប ត្រាស់បួនអង្គហៅថាសារមណ្ឌកប្ប ត្រាស់ប្រាំអង្គហៅថាភទ្ទកប្ប។ ក្នុងភទ្ទកប្បដែលមានព្រះពុទ្ធត្រាស់ដឹង៥ព្រះអង្គនោះ ព្រះពុទ្ធ៤ព្រះអង្គបានត្រាស់ដឹងនិងបរិនិព្វានទៅហើយ។ ព្រះពុទ្ធទី៤ដែលបរិនិព្វានហើយប៉ុន្តែនៅធម៌វិន័យទុកឲ្យមនុស្សសត្វប្រតិបត្តិ

សព្វថ្ងៃនេះ គឺព្រះពុទ្ធព្រះនាមសមណគោតម។ ចំណែកព្រះពុទ្ធទី៥គឺព្រះពុទ្ធព្រះនាមព្រះសិអារ្យមេត្រីពុំទាន់ត្រាស់ដឹងនៅឡើយ។ ព្រះពុទ្ធសមណគោតម ព្រះអង្គត្រាស់ដឹងក្នុងព្រះជន្ម៣៥ព្រះវស្សាហើយបរិនិព្វានក្នុងព្រះជន្ម៨០ព្រះវស្សា ក្នុងពេលដែលព្រះអង្គបានសំដែងធម៌ទេសនាប្រោសសត្វអស់រយៈពេល៤៥ព្រះវស្សារួចហើយ។ ចម្លើយទៅនឹងសំនួរថា បន្ទាប់ពីព្រះអង្គបរិនិព្វានទៅ តើសាសនាព្រះអង្គត្រូវអស់ត្រឹមនេះឬនៅមានជាបន្តទៅទៀត? ព្រះអង្គបានឆ្លើយទៅកាន់សាវករបស់ព្រះអង្គថា តាមដែលព្រះអង្គប្រមើមើលទៅអនាគត សាសនាព្រះអង្គមនុស្សសត្វអាចទទួលប្រតិបត្តិតាមចំនួន៥០០០ឆ្នាំទៅមុខទៀត។ តាមចម្លើយរបស់ព្រះអង្គនេះបញ្ជាក់ថា ព្រះអង្គបរិនិព្វានទៅប៉ុន្តែនៅធម៌វិន័យដែលព្រះអង្គបានសំដែងហើយ ទុកសំរាប់មនុស្សសត្វប្រតិបត្តិតាម។ ឥឡូវនេះសាសនាព្រះពុទ្ធសមណគោតមកន្លងបានជាងពាក់កណ្តាលហើយ។ បន្ទាប់ពីគ្រប់៥០០០ឆ្នាំ ព្រះពុទ្ធទី៥គឺព្រះសិអារ្យមេត្រីពុំទាន់ត្រាស់ដឹងនៅឡើយទេ គឺរាប់ពាន់រាប់ម៉ឺនឆ្នាំទៅមុខទៀតទើបព្រះអង្គត្រាស់ដឹង។

ព្រះសិអារ្យមេត្រី ព្រះអង្គកើតក្នុងត្រកូលព្រាហ្មណ៍ដែលជាធំក្នុងនគរកេតុមតី មាតារបស់ព្រះអង្គព្រះនាមព្រហ្មវតី បិតាព្រះនាមសុព្រហ្មា។ សម័យនោះ មនុស្សបរិបូណ៌ដោយសេចក្តីសុខ។ ព្រះសិអារ្យមេត្រី ព្រះអង្គមានព្រះជន្ម

វែង ការសំដែងធម៌ទេសនាក៏បានយូរអង្វែង។ កាលព្រះពុទ្ធព្រះនាមសិអារ្យមេត្រីបរិនិព្វានកន្លងយូរបន្តិចទៅទៀត ភទ្ទកប្បផែនដីយើងនេះដល់កំណត់អាយុហើយ ក៏ត្រូវភ្លើងឆេះរំលាយឲ្យវិនាសក្នុងពេលនោះឯង។ សម័យព្រះពុទ្ធសិអារ្យមេត្រីមនុស្សមានសេចក្ដីសុខច្រើន ដូច្នេះហើយបានជាពុទ្ធសាសនិកជនខ្មែរធ្វើបុណ្យប្រាថ្នាជួបព្រះសិអារ្យមេត្រីដើម្បីបានសម្រេចមគ្គផលនិព្វាន។ តាមពិត ពុំគួររង់ចាំព្រះសិអារ្យមេត្រីទេ គួរប្រតិបត្តិតាមធម៌របស់ព្រះពុទ្ធសមណគោតមឲ្យបានសម្រេចមគ្គផល ព្រោះបើរង់ចាំត្រូវកើតចាស់ឈឺស្លាប់យូរអង្វែងណាស់។ ព្រះពុទ្ធគ្រប់ព្រះអង្គទាំងអតីតៈបច្ចុប្បន្ននិងអនាគត មានការត្រាស់ដឹងធម៌ដូចគ្នា។ ដូច្នេះការជួបព្រះពុទ្ធណាក៏ដូចព្រះពុទ្ធណាដែរ សំខាន់នៅលើការស្ដាប់ធម៌បានហើយយកមកប្រតិបត្តិតាម ព្រះពុទ្ធគ្រាន់តែបង្ហាញផ្លូវប្រតិបត្តិប៉ុណ្ណោះ។

ចំពោះអ្នកផ្សាយគ្រិស្តសាសនាខ្មែរ ដោយសង្កេតឃើញថាពុទ្ធសាសនិកជនខ្មែរយកចិត្តទុកដាក់ព្រះពុទ្ធព្រះសិអារ្យមេត្រីដែលពុំទាន់បានត្រាស់ ពួកគេក៏បានឆ្លៀតឱកាសឃោសនាដោយបន្លំថាព្រះយេស៊ូនៃសាសនាគ្រិស្តនេះហើយជាព្រះសិអារ្យមេត្រី ជាព្រះសង្គ្រោះព្រះអង្គយាងមកហើយ។ វិធីឃោសនាដោយការបញ្ឆោតនេះ ពុទ្ធសាសនិកជនខ្មែរគ្មានការយកចិត្តទុកដាក់ឡើយ ដោយដឹងច្បាស់ថា

នេះគ្រាន់តែជាល្បិចរបស់អ្នកផ្សាយគ្រិស្តសាសនា ដោយឃោសនាអែបនឹងព្រះពុទ្ធសាសនាដើម្បីទាក់ទាញជំនឿទៅលើព្រះយេស៊ូ។ ដូចបានរៀបរាប់មកហើយ ព្រះពុទ្ធព្រះសិអារ្យមេត្រីពុំទាន់ត្រាស់ដឹងនៅឡើយទេ ព្រោះតាមធម្មតាព្រះពុទ្ធពុំដែលត្រាស់ដឹងពីរព្រះអង្គក្នុងពេលជាមួយគ្នាឡើយ ព្រោះការឃើញសច្ចធម៌ ឃើញដូចតែគ្នា ទោះបីព្រះពុទ្ធត្រាស់ដឹងកន្លងមកហើយក្តី បច្ចុប្បន្ននេះក្តី និងត្រាស់ដឹងនៅពេលជាអនាគតក្តី។ ដូច្នេះ អ្នកផ្សាយគ្រិស្តសាសនាឃោសនាខុសពីការពិត ដោយចាត់ទុកព្រះយេស៊ូជាព្រះសិអារ្យមេត្រីនោះ នាំឲ្យខូចតម្លៃខ្លួនឯងទេ ហើយការឃោសនានេះមិនខុសគ្នាពីសាសនាព្រាហ្មណ៍ដែលចាត់ទុកព្រះពុទ្ធជាអវតារទី៩នៃព្រះវិស្ណុក្នុងគោលបំណងដើម្បីទាញពុទ្ធសាសនិកជនដែលជឿព្រះពុទ្ធមានចំនួនកាន់តែច្រើនឡើងឲ្យចូលកាន់សាសនាព្រាហ្មណ៍វិញ ព្រោះព្រះពុទ្ធជាតួអង្គបែងភាគពីព្រះវិស្ណុទេ។ ដោយពិបាកបង្វែគំនិតខ្មែរឲ្យជឿគ្រិស្តសាសនាពេក អ្នកផ្សាយគ្រិស្តសាសនាបានប្រើវិធីមួយទៀត គឺគេលើកយកពាក្យព្រះពុទ្ធខ្លះមកប្រើដូចជាពាក្យថាបាបបុណ្យគុណទោសជាដើម ដើម្បីឲ្យពុទ្ធសាសនិកជនខ្មែរច្រឡំថាគ្រិស្តសាសនាមានពាក្យប្រៀនប្រដៅកន្លែងខ្លះដូចពុទ្ធសាសនាដែរ។ តាមពិតវិញ ពាក្យប្រៀនប្រដៅខុសគ្នាស្រឡះ គឺព្រះពុទ្ធសាសនា សេចក្តីសុខទុក្ខចំរើនវិនាសស្ថិតនៅលើអំ

ពើរបស់ខ្លួន ចំណែកគ្រិស្តសាសនាវិញ សេចក្ដីសុខទុក្ខ
អើនវិនាសស្ថិតនៅលើព្រះជាម្ចាស់គឺព្រះយេហូវ៉ា បើលោក
សព្វព្រះទ័យលោកនឹងផ្ដល់សុខឲ្យ បើលោកមិនសព្វព្រះ
ទ័យទេ លោកនឹងផ្ដល់ទុក្ខឲ្យ មានឲ្យធ្លាក់នរកជាដើម។

## ៧- ព្រះពិតគឺព្រះពុទ្ធក្នុងព្រះពុទ្ធសាសនា

ពាក្យថា **ព្រះ**មកពីពាក្យបាលីថា**វរៈ**ប្រែថា**ប្រសើរ** ផ្លាស់វជាព ឯវផ្លាស់ធ្វើជាជើងទៅជា**ព្រះ**ប្រែថា**ប្រសើរ**។ ពាក្យ**ព្រះ**នេះ សំរាប់ដាក់ពីមុខនាមចំពោះបុគ្គលឬវត្ថុដែលមានគុណធម៌ឬមានប្រយោជន៍ ដូចពាក្យថាព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ព្រះមាតាព្រះបិតា រហូតប្រើជាមួយធម្មជាតិដែលមានប្រយោជន៍ដូចពាក្យថា ព្រះអាទិត្យ ព្រះចន្ទ ព្រះធរណី ជាដើម។ ម៉្យាងទៀត ពាក្យ**ព្រះ**នេះ គេអាចប្រើតែម្នាក់ឯងសំរាប់បុគ្គលដែលគេលើកតម្កើង ថាជាកំពូលនៃលោកគ្មានបុគ្គលណាស្មើ ដូចជា**ព្រះពុទ្ធ**ជាដើម។ សាសនាដទៃ ក្រៅពីពុទ្ធសាសនាតែងឲ្យតម្លៃខ្លួនឯងថា **ព្រះ**ពិតប្រាកដ គឺព្រះបង្កើតលោក ចំណែកព្រះពុទ្ធមិនបង្កើតលោកពុំមែនជា ព្រះពិតប្រាកដទេ គឺគ្រាន់តែជាគ្រូបង្រៀនប៉ុណ្ណោះ។ គេថា **ព្រះ**របស់គេបង្កើតលោក ប៉ុន្តែគេពុំអាចរកភ័ស្តុតាងត្រង់ណាដែលបញ្ជាក់ថាព្រះសាងលោក ឬបង្កើតលោកពិតមែន។ មួយទៀត គួរឲ្យស្តាយបើព្រះបង្កើតលោកពិតមែនគួរណាស់តែបង្កើតមនុស្សនិងវត្ថុល្អៗ ដើម្បីឲ្យបានសុខចំរើនដល់សង្គម ពុំគួរបង្កើតមនុស្សមានចិត្តអាក្រក់ ពុំគួរបង្កើតរន្ទះបាញ់ ភ្លើងឆ្នំផ្ទុះ រញ្ជួយផែនដី ដូចពេលថ្មីៗនេះ មានរញ្ជួយបាតសមុទ្រហៅថា Tsunami ធ្វើឲ្យមនុស្សជាង១សែននាក់

ត្រូវស្លាប់ របួស៥សែននាក់ និងគ្មានជំរក៥លាននាក់ និងសំណង់ផ្សេងៗក៏ត្រូវវិនាស។ តើព្រឹត្តិការណ៍ទាំងអស់នេះ ព្រះលោកបង្កើតពិតមែន ឬជាច្បាប់ធម្មជាតិនិងច្បាប់កម្មផល ដូចវិទ្យាសាស្រ្ត និងព្រះពុទ្ធសាសនាពោលទេ? ព្រហ្មញ្ញសាសនាក៏ថាព្រះព្រហ្មបង្កើតលោក គ្រិស្តសាសនាក៏ថាព្រះអាទិទេពគឺព្រះយេហូវ៉ាបង្កើតលោក ឥស្លាមសាសនាក៏ថា ព្រះអាទិទេពគឺព្រះអាឡាបង្កើតលោក ចុះបើបង្កើតលោកដូចគ្នាដូច្នេះ តើព្រះណាពិតប្រាកដដែលបង្កើតលោក ឬគ្រាន់តែចម្លងតាមគ្នា ព្រោះសាសនាព្រាហ្មណ៍កើតមុនសាសនាទាំងពីរ? គេចង់ដឹងមួយទៀតថា តើអ្នកណាបង្កើតព្រះទាំងនោះ តើព្រះទាំងនោះមានមាតាបិតាមានរូបរាងបែបម៉េចហើយនៅឯណា?

ចំពោះព្រះពុទ្ធវិញ ព្រះអង្គមានជាតិជាមនុស្សមានព្រះមាតាបិតាមានទីកន្លែងពិតប្រាកដ មានរយៈពេលការស្វែងរកធម៌ បានត្រាស់ដឹងធម៌ បានសំដែងធម៌ប្រោសសត្វ មានពាក្យប្រៀនប្រដៅរបស់ព្រះអង្គមានភ័ស្តុតាងពិតប្រាកដ ដែលអ្នកប្រវត្តិសាស្រ្តទទួលស្គាល់។ ការឃើញសច្ចធម៌៤គឺសេចក្តីទុក្ខ ទើបឈ្មោះថា **ព្រះអង្គត្រាស់ដឹង** គឺត្រាស់ដឹងនូវធម៌ចេញចាកទុក្ខ ទើបព្រះនាមកើតឡើងថា **ពុទ្ធោ** ឬ **សម្មាសម្ពុទ្ធោ** ដែលភាសាខ្មែរថា **ព្រះពុទ្ធ** នេះឯង។ ព្រះនាមរបស់ព្រះពុទ្ធមួយបទថា លោកវិទូ ប្រែថាព្រះអង្គត្រាស់

ដឹងនូវលោក។ បានសេចក្តីថា លោកនិងរចនាសម្ពន្ធរបស់លោកកើតមានជាធម្មតា ពុំមែនព្រះជាម្ចាស់អង្គណាបង្កើតឡើងទេ ឯព្រះពុទ្ធក៏ឃើញការពិតនោះ។ លោកដែលព្រះអង្គត្រាស់ដឹងមានបីប្រការគឺ **សត្តលោក** បានដល់មនុស្សសត្វមានវិញ្ញាណទាំងអស់ដែលអន្ទោលទៅមកស្លាប់កើតនៅភពណាជាតិណាស្របតាមអំពើរបស់ខ្លួន។ **សង្ខារលោក** សំដៅយកវត្ថុគ្មានវិញ្ញាណទាំងអស់ដូចជាព្រះអាទិត្យ ព្រះចន្ទ ផែនដី ព្រៃភ្នំ បឹងទន្លេ សមុទ្រជាដើម កើតអំពីការផ្សំធាតុដោយខ្លួនឯង។ **ឱកាសលោក** បានដល់រចនាសម្ពន្ធនិងទំនាក់ទំនងរវាងធាតុទាំងនោះ។ ធម្មជាតិទាំងនោះគ្មានអ្នកបង្កើតទេ គឺកើតពីសង្ខារ (Component, Corps composé) គឺធាតុនិងធាតុផ្គុំគ្នាកើតបានជាអ្វីមួយស្របតាមច្បាប់របស់ធម្មជាតិ ឧទាហរណ៍តាមគីមីវិទ្យា $H2+0=H2O$ គឺអីដ្រូសែន២ បូកនឹងអុកស៊ីសែន១ កើតបានជាទឹកជាដើម។ ព្រះពុទ្ធសំដែងថា អ្វីទាំងអស់កើតពីការផ្សំ(សង្ខារ) រវាងហេតុបច្ច័យដែលវិទ្យាសាស្ត្រថា ការផ្សំបរមាណូធាតុល្អិតជាទីបំផុតកើតបានជាម៉ូលីគីល (Molicule) ផ្សំគ្នាច្រើនទៀតទើបកើតបានជាអង្គធាតុ (organ)។ ដូច្នេះបញ្ជាក់ថា វត្ថុធាតុពុំមានតួខ្លួនវាពិតទេ គឺកើតពីការផ្សំធាតុដី ទឹក ភ្លើង ខ្យល់ នេះឯង។ ដូចជាបេះដូងរបស់មនុស្ស វាមានសាច់សំរាប់ឲ្យមានចលនាកំរើកជានិច្ច បើវាខូចផ្នែកនោះ វាត្រូវឈប់ដើរ ទោះបីអាទិទេព

បញ្ជាក៏វាមិនដើរដែរ ប៉ុន្តែបើសាច់ផ្នែកនោះនៅល្អ វាតែងដើរជាធម្មតា ទោះបីអាទិទេពមិនបញ្ជាក៏ដោយ។ ដូច្នេះ ព្រះពុទ្ធត្រាស់ដឹងនូវច្បាប់ធម្មជាតិ (natural law, loi de la nature) ហើយយកមកប្រកាសប្រាប់មនុស្សសត្វទាំងអស់គ្នា។ ព្រះអង្គគ្រាន់តែបង្ហាញផ្លូវ(អក្ខាតារោ តថាគតោ=show the way) ឲ្យមនុស្សសត្វដើរដោយខ្លួនឯង ព្រះអង្គពុំអាចទទួលបាបមនុស្សសត្វបានទេ ព្រោះសេចក្ដីបរិសុទ្ធនិងមិនបរិសុទ្ធដោយខ្លួនឯង អ្នកដទៃពុំអាចញុំាងអ្នកដទៃឲ្យបរិសុទ្ធឬសៅហ្មងបានឡើយ (សុទ្ធិ អសុទ្ធិ បច្ចត្តំ នាញ្ញោ អញ្ញំ វិសោធយេ)។ ឯសាសនាដទៃ ដែលថាសាសនាគេទទួលយកបាបនោះក៏គ្មានទំនាក់ទំនងរវាងហេតុនិងផលយកជាការបានឡើយ។ អ្នកធ្វើអំពើបាបសៅហ្មងចិត្ត បើពុំដុសខាត់ចិត្តឲ្យស្អាតដោយខ្លួនឯងទេ ក៏គ្មានបុគ្គលណាអាចដកចិត្តសៅហ្មងនោះចេញពីចិត្តខ្លួនបានឡើយ។ ក៏ដូចជាគ្រូបង្រៀនខំពន្យល់សិស្សនូវមុខវិជ្ជាណាមួយ បើសិស្សនោះពុំយកចិត្តទុកដាក់ស្ដាប់ទេ គ្រូពុំអាចបញ្ចូលវិជ្ជានោះទៅក្នុងខួរក្បាលសិស្សបានឡើយ។ ព្រះពុទ្ធសំដែងបាបនិងបុណ្យ ប៉ុន្តែព្រះអង្គពុំសម្រេចថាឲ្យអ្នកនេះទទួលផលបាបឲ្យអ្នកនោះទទួលផលបុណ្យឡើយ គឺបាបបុណ្យឲ្យផលដោយខ្លួនឯងជាស្វ័យប្រវត្តិ អាងដោយពុទ្ធភាសិតថា កម្មផលបែងចែកសត្វឲ្យខ្ពង់ខ្ពស់និងថោកទាប។

សរុបសេចក្តីមក **ព្រះ**ពិតប្រាកដនោះ គឺបុគ្គលដែលរកឃើញអរិយសច្ចធម៌ ដែលជាមាគ៌ាដឹកនាំមនុស្សសត្វចេញចាកទុក្ខពិតប្រាកដ គឺ**ព្រះពុទ្ធក្នុងព្រះពុទ្ធសាសនា**នេះឯង។ ព្រះអង្គត្រាស់ដឹងដោយប្រើប្រដាប់ផ្លូវគឺអរិយមគ្គញ្ញាណដោយប្រាជ្ញាដ៏មុតថ្លា។ ព្រះអង្គជាបុគ្គលឈ្នះលោក ពុំវិលវល់ជាប់ជំពាក់វង្វេងក្នុងលោកឡើយ។ ដោយមានការអាណិតអាសូរមនុស្សសត្វដែលកំពុងមានទុក្ខវិលស្លាប់វិលកើតក្នុងសង្សារវដ្ត ទើបព្រះអង្គសំដែងធម៌ប្រោស ហាក់ដូចជាពន្លឺដែលបំភ្លឺក្នុងទីងងឹត។ មូលហេតុដែលនាំឲ្យកើតជាតិប្រកបដោយខន្ធ៥មកពី អវិជ្ជា តណ្ហា ឧបាទាន និងកម្ម។ ការកើតឡើងនៃខន្ធ៥មានរូបក្ខន្ធជាដើមជាតួទុក្ខ ព្រោះកាលណាមានជាតិតែងតែបញ្ជូនទៅរកជរាព្យាធិនិងមរណៈតទៅទៀត។ ដូច្នេះ បើមានព្រះជាម្ចាស់អង្គណាបង្កើតខន្ធ៥ដែលជាតួទុក្ខនេះ ចាត់ទុកជាមូលហេតុបង្កើតទុក្ខដល់មនុស្សសត្វដូចអវិជ្ជាតណ្ហាឧបាទានកម្មដែរ។ ព្រះពុទ្ធសាសនាសំដែងថា សេចក្តីទុក្ខទាំងអស់កើតមកអំពីការមានជាតិគឺមានខន្ធ៥នេះឯង។ ដើម្បីកុំឲ្យមានជាតិជាតួទុក្ខ ត្រូវកំចាត់បង់ហេតុដែលនាំឲ្យកើតទុក្ខ គឺបំបាត់អវិជ្ជា តណ្ហា ឧបាទាននិងកម្មកុំឲ្យមានសេសសល់។ ជនជាតិខ្មែរធ្លាប់មានអារ្យធម៌ខ្ពង់ខ្ពស់តាំងពីសម័យបូរាណ បានគោរពព្រះពុទ្ធសាសនាទុកជាមាគ៌ាប្រចាំជីវិតរបស់ខ្លួន ដោយពិចារណាឃើញថា ព្រះពុទ្ធ

សាសនាមានពាក្យប្រៀនប្រដៅដ៏ត្រឹមត្រូវក្នុងការដឹកនាំខ្លួន និងសង្គមខ្មែរ ឲ្យបានសុខសាន្ត។ ដូចបានពោលមកហើយ របស់អ្វីមួយបានកើតឡើង សុទ្ធតែកើតឡើងពីហេតុបច្ច័យ គ្មានអ្វីមួយកើតឡើងប្រាសចាកហេតុបច្ច័យឡើយ។ ព្រះពុទ្ធ សំដែងថា គ្រប់ធម្មជាតិទាំងអស់កើតឡើងដោយខ្លួនឯង តាមធម្មតារបស់លោកធាតុឬចក្រវាឡ ដូចព្រះអាទិត្យ ព្រះ ចន្ទ ផែនដី ភ្នំទន្លេ សមុទ្រជាដើម គ្មានអ្នកបង្កើតទេ។ ឯ របស់មានវិញ្ញាណដូចមនុស្សសត្វអន្ទោលស្លាប់កើតតាមអំ ពើរបស់ខ្លួន ពុំមែនព្រះពុទ្ធជាអ្នកចាត់ចែងទេ។ មួយទៀត ព្រះពុទ្ធពុំសំដែងត្រង់ណាដែលពុំអាចលើកយកភ័ស្តុតាងមក បញ្ជាក់ប្រាប់គេបានឡើយ ដូចព្រះអង្គមិនសំដែងថាក្នុង លោកនេះ តើមនុស្សណាឈ្មោះអ្វីកើតមុនគេ។ ព្រះអង្គមាន ព្រះពុទ្ធដីកាដោយលើកយកឧទាហរណ៍មួយមកបញ្ជាក់ថា បើគេសួរថា កូនមាន់កើតមកពីណា មុខជាឆ្លើយថា កើតមក ពីពងមាន់ ចុះពងមាន់កើតមកពីណា មុខជាឆ្លើយថាកើតមក ពីមេមាន់ ចុះមេមាន់កើតមកពីណា មុខជាឆ្លើយដដែលកើត ពីពងមាន់កូនមាន់ ពុំអាចកំណាត់បានថា មាន់ណាកើតមុន គេដែលអាចយកភ័ស្តុតាងមកបញ្ជាក់ប្រាប់គេបានឡើយ។ ព្រះពុទ្ធបានបញ្ជាក់បន្ថែមទៀតថា ប្រៀបដូចកង់រទេះមួយ ដែលមានរង់មូលគេបង្វិលឲ្យវិល គេពុំអាចកំណត់ថា ត្រង់ ណាជាចំណុចដើមឡើយ។ ព្រះពុទ្ធសាសនាក៏គ្មានពាក្យ

ប្រៀនប្រដៅថា មនុស្សដើមដែលកើតមុនគេធ្វើបាប វាមានបាបដល់មនុស្សក្រោយទៀតដែលមិនបានធ្វើបាបដូចនេះឡើយ។ នេះជាទ្រឹស្ដីអយុត្តិធម៌ណាស់ ព្រោះមនុស្សមុនមិនជឿព្រះ ព្រះអង្គឲ្យមានបាប ឲ្យបាបដល់អ្នកកើតក្រោយទៀត។ តុលាការបច្ចុប្បន្ននេះ គេសម្រេចឲ្យមានទោសចំពោះមនុស្សណាដែលប្រព្រឹត្តខុស។ ពុំមែនបានន័យថាឪពុកម្ដាយប្រព្រឹត្តខុសមានទោសតាមផ្លូវរដ្ឋ កូនដែលមិនបានប្រព្រឹត្តក៏ត្រូវមានទោសដូច្នេះឡើយ។ ក្នុងពុទ្ធសាសនាក៏និយាយថា អ្នកដែលធ្វើបាបត្រូវទទួលផលបាបដោយខ្លួនឯង។ ក្នុងព្រះពុទ្ធសាសនាក៏គ្មានទ្រឹស្ដីថា មនុស្សណាជឿព្រះអង្គមានភក្ដីភាពចំពោះព្រះអង្គ ព្រះអង្គសព្វព្រះទ័យឲ្យមនុស្សនោះកើតក្នុងស្ថានសួគ៌ ឯមនុស្សណាដែលមិនស្ដាប់បង្គាប់ ព្រះអង្គដាក់បណ្ដាសារ មនុស្សនោះនឹងទទួលទុក្ខទោសរហូតឲ្យធ្លាក់នរកយ៉ាងនេះឡើយ។ ព្រះពុទ្ធជាបុគ្គលបរិសុទ្ធផុតចាកការបៀតបៀនហើយ ព្រះអង្គមិនឲ្យមនុស្សកើតស្ថានសួគ៌និងចុះនរកដោយសារមិនជឿព្រះអង្គឡើយ ប៉ុន្តែព្រះអង្គគ្រាន់តែបង្ហាញផ្លូវទៅកាន់ទីសុខទុក្ខប៉ុណ្ណោះ ទុកសិទ្ធិឲ្យមនុស្សសត្វសម្រេចចិត្តធ្វើដំណើរដោយខ្លួនឯង។ សូម្បីព្រះអង្គសំដែងធម៌ ក៏គ្មានបង្ខំមនុស្សសត្វឲ្យជឿធម៌ព្រះអង្គឡើយ ថែមទាំងព្រះអង្គរំលឹកថា មុននឹងជឿធម៌តថាគត ចូរអ្នកពិចារណាជាមុនសិន។ បរិស័ទគ្រប់សាសនាទាំងអស់

ក៏ពុំមែនប្រតិបត្តិបានត្រឹមត្រូវតាមឱវាទសាសនារបស់ខ្លួនឡើយ តែងលាយឡំដោយទំនៀមទម្លាប់ប្រពៃណីជាតិដែលមានជាច្រើនតំណមក។ យ៉ាងណាមិញ ជនជាតិខ្មែរពេលមានទុក្ខតែងបន់ស្រន់ឲ្យខ្លួនបាត់ទុក្ខជាដើម ក៏ដូចជាព្រះសង្ឃសូត្រធម៌ជូនពរពុទ្ធបរិស័ទជាការលើកទឹកចិត្តឲ្យមានកម្លាំងផ្លូវចិត្តតាមរបបសុជីវធម៌ ជាមួយនោះបានប្រទានឱវាទឲ្យគេប្រព្រឹត្តល្អដើម្បីឲ្យការជូនពរនោះមានប្រសិទ្ធិភាពពុំមែនជាការខុសទេ។ មានសាសនាមួយនិយាយថា ព្រះរបស់គេបង្កើតលោក ឯព្រះពុំមានសាច់ឈាមរាងកាយអ្វីឡើយ គឺទ្រង់ជាព្រះវិញ្ញាណ។ ព្រះពុទ្ធសាសនានិយាយថាវិញ្ញាណកើតមានអាស្រ័យមានរូប គឺអាយតនៈ៦ ភ្នែកត្រចៀកច្រមុះអណ្តាតកាយនិងមនោ ប៉ះ (ផស្សៈ) នឹងអាយតនៈ ខាងក្រៅរូបសម្លេងក្លិនរសសម្ផស្សនិងធម្មា(ធម្មារម្មណ៍) ទើបកើតចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណជីវ្ហាវិញ្ញាណ កាយវិញ្ញាណ និងមនោវិញ្ញាណ។ ដូច្នេះ ព្រះជារបស់អវិជ្ជមានទៅបង្កើតរបស់វិជ្ជមាន តើមានការពិតឬទេ? សាសនានោះនិយាយទៀតថា ព្រះបង្កើតអ្វីទាំងអស់ គ្មានវត្ថុនិងមនុស្សណាដែលព្រះមិនបង្កើតនោះទេ ព្រះធ្វើអន្តរាគមន៍បញ្ហាមនុស្សលោកតាំងពីនយោបាយទៅរហូតទ្រង់អនុញ្ញាតឲ្យកើតខ្យល់ព្យុះ ភ្លើងភ្នំផ្ទុះជាដើម ដោយមនុស្សមិនស្តាប់បង្គាប់ទ្រង់ ទ្រង់ត្រូវតែដាក់បណ្តាសារដូច្នេះ។ អស្ចារ្យ

ណាស់ គ្រាន់តែគេមិនស្តាប់បង្គាប់មិនធ្វើតាម ទៅធ្វើបាបគេ នេះទុកជាការរំលោភសិទ្ធិនៃជំនឿរបស់គេ ដែលផ្ទុយពីរបប ប្រជាធិបតេយ្យនិងយុត្តិធម៌។ ចំពោះព្រះពុទ្ធនៃព្រះពុទ្ធ សាសនាវិញ ព្រះអង្គមិនមានព្រះទ័យធ្វើទោសបុគ្គលណា ឡើយ ទោះបីគេមិនជឿធម៌ទេសនាព្រះអង្គក៏ដោយ ដូចពួក និគ្រន្ថមិនជឿហើយប្រឆាំងនឹងព្រះអង្គក៏មិនឃើញក្នុងពុទ្ធ ប្រវត្តិថាព្រះអង្គតបទៅពួកនិគ្រន្ថទាំងនោះដោយហឹង្សាបែប ណាមួយឡើយ។ សាសនានោះនិយាយបន្តទៀតថា គ្មានអ្វី មួយដែលព្រះបង្កើតឡើងដោយឥតប្រយោជន៍ឡើយ។ សូមសួរតែវត្ថុមួយថា ចុះពោះវៀនដុះខ្នែង ដែលព្រះបង្កើត ឲ្យមនុស្សមានគ្រប់គ្នា ដើម្បីអ្វី? នៅពេលដែលវាហើម ត្រូវ ឈឺចុកចាប់ បើមិនកាត់ចោលឲ្យទាន់ពេលវេលាទេ នឹង ទទួលគ្រោះថ្នាក់រហូតដល់ទទួលមរណភាព។ គេពោលថា ព្រះបង្កើតមនុស្សច្រើនធុនមានល្អមានអាក្រក់ ដើម្បីដឹង ល្អត្រូវមានអាក្រក់។ ពាក្យនេះមានន័យថា គ្រាន់តែឲ្យគេ ដឹងល្អ ទៅជាបង្កើតមនុស្សអាក្រក់ ឲ្យពិភពលោកមានទុក្ខ ដោយសារមនុស្សអាក្រក់ដែលព្រះបង្កើតនេះបៀតបៀន។ អ្នកមានវិជ្ជាមានបញ្ញាគេយល់លក្ខណៈមនុស្សហើយ មិន បាច់បង្កើតមនុស្សអាក្រក់ទើបដឹងមនុស្សល្អទេ។ គេពោល ថាមនុស្សពិការ មានមនុស្សខ្វាក់ជាដើម ពុំមែនកើតឡើង ដោយបាបខ្លួនឯង និងដោយឪពុកម្តាយទេ តែកើតឡើងពី

ព្រះជាម្ចាស់បណ្តាលឲ្យពិការមានខ្វាក់ជាដើម ទើបព្រះអង្គព្យាបាលឲ្យជា ដោយព្រះសំដែងក្នុងខ្លួនមនុស្សខ្វាក់នោះ ដើម្បីសំដែងការលើកតម្កើងសិរីរុងរឿងនៃព្រះជាម្ចាស់។ ពាក្យនេះមានន័យថា មនុស្សពិការមានខ្វាក់ជាដើមនេះគឺព្រះធ្វើឲ្យខ្វាក់។ គ្រាន់តែចង់តម្កើងព្រះបែរជាទៅធ្វើទុក្ខទោសដល់មនុស្ស ធ្វើឲ្យគេឈឺហើយទៅព្យាបាល។ ឥឡូវនេះ មនុស្សពិការខ្វាក់ខ្វិនគរថ្លង់ច្រើនណាស់ សូមព្រះយាងមកជួយព្យាបាលផង ដើម្បីជួយសម្រាលគ្រូពេទ្យកុំឲ្យចំណាយថវិកាជាតិច្រើនពេក។ គេពោលថា មនុស្សមានទុក្ខដោយសារមានបាប ខុសគ្នាពីព្រះពុទ្ធសាសនាដែលពោលថា មនុស្សមានទុក្ខដោយសារមានខន្ធ៥ (បញ្ចុបាទានក្ខន្ធាទុក្ខា)។ តើពុទ្ធសាសនានិយាយការពិតឬទេ មនុស្សចាស់ឈឺស្លាប់ដោយមានការកើត គឺការកើតមានខន្ធ៥នេះឯង។ ឯសោកទុក្ខ បរិទេវទុក្ខ ទោមនស្សទុក្ខ ឧបាយាសទុក្ខជាដើមកើតមានព្រោះមានជាតិជាបច្ច័យ។ បើមនុស្សគ្មានបាបទៅចុះ គ្រាន់តែបានសុខខ្លះក្នុងស្ថានមនុស្ស ប៉ុន្តែក៏គេចពុំផុតពីជរាទុក្ខ ព្យាធិទុក្ខ មរណទុក្ខដែរ បើកើតក្នុងស្ថានសួគ៌អស់បុណ្យត្រូវច្យុតវិលស្លាប់វិលកើតក្នុងវដ្តសង្សារដដែល។ សូមកុំបកស្រាយថា មនុស្សបើបានទៅកើតស្ថានសួគ៌ទៅរស់នៅជាមួយព្រះ មានជីវិតរស់រហូតដូច្នេះឡើយ ព្រោះស្ថានមនុស្ស ស្ថានសួគ៌ ស្ថានព្រហ្មជាភពបី ស្ថិតនៅក្រោមអនិច្ចំ ទុក្ខំ

អនត្តា ជាតួសង្ខតធម៌ តែងតែវិលស្លាប់វិលកើត មានតែព្រះនិព្វានទេ ដែលចេញផុតពីសង្ខតធាតុនេះ ជា អមតំ និព្វានំ ប្រែថា និព្វានមិនស្លាប់។ គេនិយាយថា មានតែព្រះទេដែលអាចសង្គ្រោះមនុស្សឲ្យផុតបាប ពុំមែនដោយការប្រព្រឹត្តទេ គឺដោយការស្រឡាញ់មេត្តាពីព្រះ ដោយខ្លួនមានជំនឿទៅលើព្រះ។ ចំពោះពុទ្ធសាសនាវិញពោលថា សេចក្តីបរិសុទ្ធនិងមិនបរិសុទ្ធដោយខ្លួនឯង អ្នកដទៃពុំអាចញុំាងអ្នកដទៃឲ្យបរិសុទ្ធនិងសៅហ្មងបានឡើយ។ ចិត្តជាធំជាប្រធានទៅលើសកម្មភាពល្អអាក្រក់របស់មនុស្ស បើចង់ឲ្យចិត្តបរិសុទ្ធផុតបាបត្រូវអប់រំចិត្តឲ្យប្រាសចាកកិលេសតណ្ហានិងអវិជ្ជាតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ។ ព្រះពុទ្ធសំដែងថា គ្មានឥទ្ធិពលខាងក្រៅណាមួយជួយឲ្យមនុស្សសត្វផុតទុក្ខឡើយ បើខ្លួនមិនប្រតិបត្តិខ្លួនឯងទេ។ គេពោលថា វិទ្យាសាស្ត្រគ្រាន់តែពន្យល់នូវអ្វីៗ ដែលព្រះបង្កើតឡើងប៉ុណ្ណោះ។ អ្នកដែលពោលបែបនេះ តើបានឃើញព្រះបង្កើតលោកនិងធម្មជាតិទាំងនោះដោយផ្ទាល់ខ្លួនឬសំអាងអ្វីដែលថាជាការពិតបាន ព្រោះមិនថាតែព្រះពុទ្ធសាសនាទេ ទោះបីក្រុមវិទ្យាសាស្ត្រក៏បានពោលស្របគ្នាថា ការកើតឡើងនៃធម្មជាតិនិងរចនាសម្ពន្ធរបស់ធម្មជាតិវាប្រព្រឹត្តទៅនិងកើតឡើងដោយខ្លួនវា។ គេពោលទៀតថា ពុទ្ធសាសនាពោលថា ពឹងខ្លួនឯង ចុះដូចជាមនុស្សហែលក្នុងសមុទ្រ បើមិនពឹងកប៉ាល់ឬទូកនឹងត្រូវ

ស្លាប់។ នៅតែខ្លួនពឹងខ្លួនដដែល ព្រោះអ្នកដែលគេជួយនោះ ដោយសារមនុស្សល្អដែលគួរឲ្យគេជួយ បើជាមនុស្សចោរ ប្រព្រឹត្តអំពើឧក្រិដ្ឋ គេពុំមានសទ្ធាជួយទេ។ ដូចគ្រូពន្យល់សិស្ស បើសិស្សនោះមិនជួយខ្លួនឯងដោយខំប្រឹងស្ដាប់ទេ ចំណេះវិជ្ជានោះ ពុំអាចចូលក្នុងខួរក្បាលសិស្សបានឡើយ ក៏ដូចជាពុទ្ធបរិស័ទចង់សម្រេចព្រះនិព្វានត្រូវប្រតិបត្តិខ្លួនឯង(អត្តទីបា) តាមព្រះធម៌គឺសីលសមាធិបញ្ញា(ធម្មទីបា) អ្វីដទៃទៀតពុំមែនជាទីពឹងរបស់អ្នករាល់គ្នាឡើយ(អនញ្ញសរណា) នេះជាពុទ្ធភាសិត។

## ៨- បើទទួលអំណោយមិនចូលសាសនាគ្រិស្ត តើទទួលបាបឬទេ?

តាមច្បាប់ព្រះពុទ្ធសាសនា ក៏ដូចជាច្បាប់រដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជារហូតច្បាប់អង្គការសហប្រជាជាតិ មិនមានចែងថា បើទទួលអំណោយត្រូវតែចូលសាសនាណាមួយជាពិសេសសាសនាគ្រិស្តជាដើម។ ការមិនចូលជាសិទ្ធិរបស់បុគ្គលម្នាក់ៗ ពុំមែនចូលតាមការលួងលោមឬបង្ខិតបង្ខំឡើយ។ ដូច្នេះការមិនចូលគ្មានទទួលទោសឬបាបអ្វីឡើយ។ អ្នកដែលទទួលមកពីមានអ្នកឲ្យ ដោយមិនបានទៅលួចប្លន់អ្នកណាដែលនាំឲ្យមានទោសតាមច្បាប់ឡើយ។ បើមានអ្នកឲ្យ ប៉ុន្តែគេទទួលឬមិនទទួល ក៏ជាសិទ្ធិរបស់គេ។ ជួនកាលគេមិនទទួលដោយសារអំណោយនោះមានចំណង មានលក្ខ - ខណ្ឌ ដូចជាសាសនាគ្រិស្តផ្តល់អំណោយបែបណាមួយព្រោះចង់ទាក់ទាញឲ្យគេជឿសាសនាខ្លួនសម្លាប់ព្រលឹងជាតិគេ នេះជាអំណោយមានពិសពុល។ ប៉ុន្តែបើទទួលហើយមិនធ្វើតាមលក្ខខណ្ឌដោយការបង្ខំនោះ ក៏គ្មានទោសអ្វីឡើយ។ ផ្ទុយទៅវិញ អ្នកដែលបង្ខំគេវិញទេដែលត្រូវមានទោសអំពីការរំលោភសិទ្ធិមនុស្ស ត្រង់មាត្រាថា បុគ្គលមួយរូបៗមានសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង មិនត្រូវមានការបង្ខិតបង្ខំពីជនណាឡើយ។ សរុបសេចក្តីមក បើទទួលអំណោយមិនចូលសាសនាគ្រិស្ត មិនទទួលបាបអ្វីឡើយ។

## ៩- ប្រទេសកម្ពុជាមានការសម្លាប់គ្នារាប់លាននាក់ តើបណ្តាលមកពីហេតុអ្វី?

ពាក្យប្រៀបប្រដៅរបស់ព្រះពុទ្ធ មិនថាតែមនុស្សទេ ដែលព្រះអង្គហាមមិនឲ្យបៀតបៀនមិនឲ្យសម្លាប់ ទោះបីសត្វតិរច្ឆាន ក៏ព្រះអង្គហាមដូចគ្នា ព្រោះអ្វី ? ព្រោះព្រះអង្គយល់ថា មនុស្សនិងសត្វមានការស្រឡាញ់ជីវិតមិនចង់ស្លាប់ដូចគ្នា។ ចំណែក ប្រទេសកម្ពុជាដែលមានការកាប់សម្លាប់គ្នាពីរបីទសវត្សរ៍កន្លងមកនេះ គឺជាបញ្ហានយោបាយស្រុកទេស ពុំមែនបណ្តាលមកពីព្រះពុទ្ធសាសនាឡើយ។ ការពិតយើងឃើញ ព្រះសង្ឃនិងពុទ្ធបរិស័ទ មានខ្លះរងគ្រោះដល់សុគត និងស្លាប់ដោយសារនយោបាយនោះវិញទេ។ យើងសង្កេតឃើញប្រទេសជប៉ុន និងថៃដែលកាន់ព្រះពុទ្ធសាសនាដូចប្រទេសកម្ពុជា គេគ្មានការកាប់សម្លាប់គ្នាដូចប្រទេសកម្ពុជា មកពីគេមាននយោបាយដឹកនាំល្អ រហូតធ្វើឲ្យសេដ្ឋកិច្ចគេលូតលាស់ថែមទៀត។ ដូច្នេះ បញ្ជាក់ថា បើអនុវត្តតាមព្រះពុទ្ធសាសនាឲ្យម៉ត់ចត់ មិនត្រឹមតែមិនប្រើហឹង្សាសម្លាប់គ្នា ហើយចំរើនខាងសីលធម៌ប៉ុណ្ណោះទេ ថែមទាំងលូតលាស់ខាងផ្នែកសង្គមកិច្ចទៀតផង។ ផ្ទុយទៅវិញ មានប្រទេសខ្លះកាន់សាសនាគ្រិស្ត និងសាសនាមូស្លីម នៅមជ្ឈិមបូព៌ា និងនៅអាហ្វ្រិក កំពុងវាយកាប់សម្លាប់គ្នារៀងរាល់ថ្ងៃមិនទាន់ចប់នៅឡើយ។ ដូច្នេះ ការកាប់សម្លាប់គ្នានៅប្រទេស

កម្ពុជានេះ ពុំមែនបណ្ដាលមកពីព្រះពុទ្ធសាសនាឡើយ គឺបណ្ដាលមកពីការដឹកនាំស្រុកទេស ពុំគោរពតាមធម៌របស់ព្រះពុទ្ធវិញទេ។

# ១០- ការប្រៀនប្រដៅល្អខុសគ្នា រវាងពុទ្ធសាសនានិងសាសនាដទៃ

គោលបំណងរបស់អ្នកបង្កើតឲ្យមានសាសនា តែងបំណងឲ្យបរិស័ទរបស់ខ្លួនបានសុខ ប៉ុន្តែមធ្យោបាយទៅរកបំណងនោះ ពិតជាមានលក្ខណៈផ្សេងគ្នា។ បើនិយាយពីភាពល្អមានបីថ្នាក់គឺៈ ទី ១- ល្អធម្មតា ២- ល្អដោយប្រៀបធៀបគ្នា ៣- ល្អបណ្តាច់គឺល្អដាច់គេ។ ចំពោះព្រះពុទ្ធសាសនាធម៌វិន័យរបស់ព្រះអង្គ ដែលប្រៀនប្រដៅមនុស្សសត្វជាធម៌បរិសុទ្ធជាធម៌មិនបៀតបៀន។ លក្ខណៈវិនិច្ឆ័យធម៌វិន័យ ៨ប្រការតទៅនេះ ចាត់ជាធម៌វិន័យរបស់ព្រះពុទ្ធគឺៈ

១- វិរាគាយៈ ប្រព្រឹត្តទៅដើម្បីប្រាសចាកតម្រេក

២- វិសំយោគាយៈ ប្រព្រឹត្តទៅដើម្បីប្រាសចាកទុក្ខ

៣- អបចយាយៈ ប្រព្រឹត្តទៅដើម្បីមិនសន្សំកិលេស

៤- អប្បិច្ឆតាយៈ ប្រព្រឹត្តទៅដើម្បីប្រាថ្នាតិច

៥- សន្តុដ្ឋិយា ប្រព្រឹត្តទៅដើម្បីសេចក្តីត្រេកអរចំពោះវត្ថុតាមមានតាមបាន

៦- បវិវេកាយៈ ប្រព្រឹត្តទៅដើម្បីស្ងាត់ចាកពួកគណៈ

៧- វីរិយារម្ភាយៈ ប្រព្រឹត្តទៅដើម្បីប្រារព្ធសេចក្តីព្យាយាម

៨- សុភរតាយៈ ប្រព្រឹត្តទៅដើម្បីការចិញ្ចឹមងាយ។

ធម៌ទាំង៨នេះគប្បីដឹងថា ជាធម៌វិន័យរបស់ព្រះពុទ្ធ។

ធម៌ផ្ទុយពីនេះ គប្បីដឹងថាមិនមែនជាធម៌វិន័យពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធឡើយ។ លក្ខណៈវិនិច្ឆ័យជាធម៌វិន័យរបស់ព្រះពុទ្ធដែលប្រៀនប្រដៅមនុស្សសត្វ តើដូចពាក្យប្រៀនប្រដៅរបស់សាសនាណាមួយឬទេ? ពិតជាពុំដូចឡើយ។

ព្រះពុទ្ធមិនបង្ខំឲ្យគេជឿ គឺព្រះអង្គគោរពសិទ្ធិមនុស្សខាងជំនឿ ដោយព្រះអង្គបានប្រកាសជាមុនថា មុននឹងជឿធម៌វិន័យដែលតថាគតសំដែង អ្នកមានសិទ្ធិពេញទីក្នុងការពិចារណាឲ្យបានល្អិតល្អន់និងធ្វើការពិសោធន៍ឲ្យយល់ច្បាស់ជាមុនសិន។ តើលក្ខណៈព្រះពុទ្ធបែបនេះ មានសាសនាណាមានលក្ខណៈដូចនេះឬទេ? ផ្ទុយទៅវិញ គេបានឮថាមានសាសនាខ្លះយកអំណោយទៅចែកឲ្យប្រជាជននៃប្រទេសក្រីក្រ ហើយបង្ខំឲ្យគេជឿនូវសាសនារបស់ខ្លួន រហូតបង្ខំកូនក្មេងដែលជាវ័យមិនទាន់ចេះពិចារណា ឲ្យជឿទៀតផង។ ចំពោះអំណោយទានតាមលក្ខណៈព្រះពុទ្ធសាសនាចំពោះជនណាម្នាក់ គឺធ្វើឡើងដើម្បីលះមច្ឆរិយៈសេចក្តីកំណាញ់ ដោយបូជាគុណក្តី ដោយសង្គហធម៌ក្តី ដោយចិត្តបរិសុទ្ធគ្មានចង់បានអ្វីមកវិញឡើយ។ នេះបញ្ជាក់ថា មានជនជាតិនៃប្រទេសអ្នកមាន កំពុងព្យាយាមបំបាត់វប្បធម៌នៃជនជាតិនៃប្រទេសអ្នកក្រ។ មានសាសនាខ្លះ បង្រៀនមិនឲ្យមនុស្សបៀតបៀនគ្នាដែរ ប៉ុន្តែមានលក្ខណៈចង្អៀតដោយមានព្រំដែនដូចជាការរក្សាសីលរបស់ពួកនិគ្រន្ថដែលហៅថា **និគន្ថ-**

**ឧបោសថ** ដែលព្រះពុទ្ធហាមមិនឲ្យរក្សាសីលតាមពួកនោះ ដូចវៀរចាកសម្លាប់សត្វទិសខាងកើតចម្ងាយមួយយោជន៍ ឯសត្វទិសដទៃសម្លាប់បាន។ សាសនាខ្លះមិនឲ្យសម្លាប់មនុស្ស តែសត្វអាចសម្លាប់បាន ព្រោះសត្វដែលសាសនាគេបង្កើតឡើងសំរាប់ជាអាហាររបស់មនុស្ស។ មានសាសនាខ្លះអនុញ្ញាតឲ្យសម្លាប់មនុស្សបើមនុស្សនោះជាសត្រូវសាសនារបស់ខ្លួន។ ចំពោះព្រះពុទ្ធសាសនាវិញ ហាមមិនឲ្យសម្លាប់ជីវិតមនុស្ស និងសព្វសត្វទាំងអស់។ បានសេចក្តីថា ឲ្យតែគេមានជីវិតសញ្ញាចង់រស់នៅមិនចង់ស្លាប់ មិនត្រូវសម្លាប់ឡើយ ត្រូវតែគោរពជីវិតមនុស្សសត្វទាំងអស់ សូម្បីតែសត្រូវរបស់ខ្លួនក៏ដោយ។ មួយទៀត គ្មានសត្វណាកើតមកសំរាប់មនុស្សស៊ីឡើយ ប៉ុន្តែសត្វត្រូវតែចាញ់ ព្រោះពុំអាចទាមទារសិទ្ធិរបស់ខ្លួនបាន។ ចំណែកព្រះពុទ្ធសាសនាឲ្យគោរពរហូតដល់សិទ្ធិសត្វ ដូចមានចែងក្នុងសិក្ខាបទទី១នៃសីល៥។ គឺជាសីលធម៌គ្មានកំណត់ព្រំដែន ជាសីលធម៌ដ៏ខ្ពង់ខ្ពស់គ្មានរបបលទ្ធិសាសនាណាប្រដូចបានឡើយ។ ដូច្នេះហើយបានជានៅឆ្នាំ ២០០៦នេះ ប្រទេសកាន់ព្រះពុទ្ធសាសនាក្នុងលោកបានប្រគល់ឲ្យប្រទេសកម្ពុជារៀបចំបុណ្យពិសាខបូជា នៅទីស្នាក់ការអង្គការសហប្រជាជាតិ ដែលបុណ្យនេះបានត្រូវអង្គការពិភពលោកនេះអនុម័តឲ្យធ្វើនៅទីស្នាក់ការរបស់ខ្លួនតាំងពីថ្ងៃទី១០ធ្នូ១៩៩៩ ដែលចាត់ទុកជាបុណ្យអន្តរជាតិ ព្រោះគេ

មើលឃើញថា ព្រះពុទ្ធសាសនាជាមូលដ្ឋាននៃការគោរព សិទ្ធិមនុស្សត្រង់ធម៌អហឹង្សាការមិនបៀតបៀន សូម្បីសត្វតិរច្ឆាន ក៏ព្រះអង្គមិនឲ្យបៀតបៀនដូចគ្នា។ ក្នុងធម្មគុណពោលថា ស្វាក្ខាតោ ប្រែថាធម៌ គឺព្រះដ៏មានព្រះភាគសំដែងល្អហើយ ត្រឹមត្រូវហើយ ជានិយ្យានិកធម៌ ជាធម៌ដឹកនាំសត្វឲ្យចេញចាក់ទុក្ខមានជាតិទុក្ខជាដើម ជាបច្ចត្តំ វេទិតព្វោ ជាធម៌ គឺព្រះអរិយបុគ្គលគប្បីដឹងពិតឃើញពិតក្នុងចិត្តនៃខ្លួន។

ដូចបានពោលមកហើយបញ្ជាក់ថា ពាក្យប្រៀនប្រដៅរបស់សាសនាដទៃមានភាពល្អខ្លះ ប៉ុន្តែជាល្អធម្មតារបស់មនុស្សបុថុជ្ជន ហើយល្អមានព្រំដែន ល្អមានលក្ខណៈខណ្ឌ ល្អពុំមានភាពបរិសុទ្ធ។ ចំណែកពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់វិញ ល្អមានភាពសុក្រឹត មានភាពបរិសុទ្ធ អាចញុំាង អ្នកប្រតិបត្តិតាមឲ្យចេញចាកទុក្ខ ជាធម៌របស់ព្រះអរិយបុ-គ្គលនាំសត្វឲ្យរំលត់ទុក្ខ ពោលគឺព្រះនិព្វានឈប់វិលកើតវិលស្លាប់។ ឯសាសនាដទៃនិយាយថា នាំសត្វទៅស្ថានព្រហ្ម និងស្ថានសួគ៌ ដែលស្ថានទាំងនោះ ព្រះពុទ្ធសំដែងថាស្ថិតក្នុងភពនៅវិលកើតវិលស្លាប់ទទួលទុក្ខវេទនាគ្មានទីបំផុតឡើយ។

## ១១- ភាតព្វកិច្ចរបស់ព្រះសង្ឃ ចំពោះពុទ្ធបរិស័ទខ្មែរ

ព្រះសង្ឃខ្មែរគ្រប់វត្តទាំងអស់ក្នុងប្រទេសកម្ពុជាទាំងមូល ក្រៅពីបំពេញកិច្ចការកសាងវត្តផ្នែកសំណង់ គប្បីបំពេញកាតព្វកិច្ចមួយផ្នែកទៀត គឺការកសាងបញ្ញាស្មារតីរបស់ពុទ្ធបរិស័ទខ្មែរដោយព្រះធម៌នៃព្រះពុទ្ធជាម្ចាស់ឲ្យពុទ្ធបរិស័ទយល់តម្លៃព្រះពុទ្ធសាសនាកាន់តែច្បាស់លាស់ឡើង។ កិច្ចការនេះ អាចអនុវត្តបាននៅគ្រប់ឱកាសបុណ្យទានក្នុងព្រះពុទ្ធសាសនា ក្រៅពីកម្មវិធីសំដែងធម៌ទេសនា អាចឆ្លៀតពេលខ្លះទៀតពន្យល់ធម៌អាចមានរយៈពេលវែងខ្លីយោល តាមពេលវេលា មុននឹងចាប់ផ្តើមសូត្រធម៌ដែលជាពិធីកម្មរបស់ព្រះពុទ្ធសាសនា។ គួរឲ្យសារៈសំខាន់ជាអាទិភាពទីមួយ គឺការពន្យល់ធម៌វិន័យដល់ពុទ្ធបរិស័ទ ឯការសូត្រធម៌ជាការសំខាន់ទីពីរ។ តាមការសង្កេត ពុទ្ធបរិស័ទច្រើនពេញចិត្តនឹងការចំរើនព្រះបរិត្ត(សូត្រមន្ត) មិនសូវសួរគ្នាថា សូត្រមន្តឬមិនសូត្រទេ ច្រើនតែសួរគ្នាថា ទេសនាឬមិនទេសន៍។ សម័-យពុទ្ធកាល សូម្បីមនុស្សតែម្នាក់ក៏ព្រះអង្គសំដែងប្រោសដែរឲ្យតែគេមានឧបនិស្ស័យគួរឲ្យព្រះអង្គប្រោសបាន។ នៅក្នុងគម្ពីរសុត្តន្តបិដក ផ្នែកព្រះសូត្រមាននិយាយថា ពេលដែលព្រះពុទ្ធឬព្រះអរហន្តទាំងឡាយទទួលទេយ្យវត្ថុមានសេនាសនៈឬចង្ហាន់ជាដើមពីពុទ្ធបរិស័ទ ព្រះអង្គបានធ្វើបត្តានុមោ-

ទនាដោយធម្មីកថា គឺការសំដែងធម៌ឲ្យពុទ្ធបរិស័ទចូលចិត្ត ក៏និមន្តជៀសចេញទៅ។ ដូច្នេះបញ្ជាក់ថា សម័យពុទ្ធកាល ព្រះពុទ្ធនិងព្រះអរហន្តបានពន្យល់ធម៌ដល់ពុទ្ធបរិស័ទដែល ប្រគេនទេយ្យវត្ថុ ពុំមែនសូត្រធម៌ទេ ការសូត្រធម៌ជូនពរកើត មានសម័យក្រោយមកទៀត។ មួយទៀត ព្រះអរហន្តបានធ្វើ បត្តានុមោទនាយ៉ាងខ្លីថា យំ យំ ឥច្ឆិតំ តំ តំ សមិជ្ឈតុ ប្រែថា សេចក្ដីប្រាថ្នារបស់អ្នកយ៉ាងណា ចូរសម្រេចយ៉ាងនោះចុះ។ ត្រង់នេះ បានសេចក្ដីថា លោកសូមជូនពរឲ្យបានសម្រេច តាមបំណងរបស់អ្នកបំពេញកុសល គឺលោកមិនអាចជួយអ្វី បានក្រៅពីអំពើល្អរបស់គេឡើយ។ សម័យក្រោយមក មាន ជូនពរថា សូមឲ្យអស់លោកបានផលយ៉ាងនេះយ៉ាងនោះ គឺជារបបសុជីវធម៌ទំនាក់ទំនងល្អក្នុងសង្គម។ ប៉ុន្តែ មានការ ជូនពរខ្លះ ជាពាក្យប្រាប់មធ្យោបាយ ដូចពាក្យថា ពរ ៤ប្រការ គឺអាយុវណ្ណៈសុខៈនិងពលៈរមែងកើតមានដល់បុគ្គលដែល មានសេចក្ដីគោរពកោតក្រែងដល់ចាស់ព្រឹទ្ធាចារ្យដល់អ្នក មានសីលជាដើម។ គឺបើចង់បានពរ៤ប្រការនេះត្រូវតែប្រតិ-បត្តិតាមធម៌ខាងលើនេះរួមជាមួយធម៌ដទៃទៀត មានការមិន សម្លាប់សត្វជាដើម។ ពុទ្ធបរិស័ទអ្នកធ្វើបុណ្យមានការធ្វើ ទានជាដើមរមែងបានបុណ្យរួចហើយដោយចេតនាល្អរបស់ ខ្លួន ទោះបីព្រះសង្ឃមិនសូត្រធម៌ជូនពរក៏នៅតែបានបុណ្យ ដដែល។ ការសូត្រធម៌ជូនពរនេះជារបបសុជីវធម៌ដើម្បីទំ

នាក់ទំនងល្អរវាងព្រះសង្ឃនិងពុទ្ធបរិស័ទ។ ដូចជាជនណាម្នាក់ដែលបានទទួលអំណោយពីជនណាម្នាក់តែងពោលថា សូមអរគុណ។ ពាក្យថាអរគុណ គឺការសំដែងអំណរចំពោះគុណគឺសេចក្តីល្អដែលគេលះវត្ថុអ្វីមួយឲ្យដល់ខ្លួន។ដូច្នេះ សូមកុំយល់ច្រឡំថា ធ្វើបុណ្យមានការធ្វើទានជាដើម បើព្រះសង្ឃមិនសូត្រធម៌ជូនពរទេ មិនបានបុណ្យយ៉ាងនេះឡើយ ព្រោះបុណ្យកើតពីអ្នកធ្វើ បុណ្យពុំមែនកើតពីអ្នកឲ្យឡើយ។

## ១២- ផលប្រយោជន៍នៃការអភិវឌ្ឍន៍ព្រះពុទ្ធសាសនានៅតាមជាយដែនខ្មែរ

ការអភិវឌ្ឍន៍ព្រះពុទ្ធសាសនានៅតាមជាយដែនខ្មែរ ជាពិសេសការបង្កើតវត្ត ពុំមែនមានប្រយោជន៍តែព្រះពុទ្ធសាសនាទេ គឺមានប្រយោជន៍ខាងការធ្វើជារបងការពារទឹកដីខ្មែររារាំងកុំឲ្យបរទេសរំកិលព្រំដែនចូលមកដីខ្មែរជាបន្តមកទៀត។ វត្តព្រះពុទ្ធសាសនាជាភ័ស្តុតាងសំខាន់ណាស់ដែលបញ្ជាក់ថាជាដីខ្មែរ។ ពុទ្ធបរិស័ទខ្មែរនៅតាមព្រំប្រទល់ដែនមានការពិបាកខាងការប្រតិបត្តិព្រះពុទ្ធសាសនា ព្រោះពុំមានវត្តអារាមនៅជិត ហើយកន្លែងខ្លះមានវត្ត ប៉ុន្តែពុំមានសេនាសនៈគ្រប់គ្រាន់ ដូចជាកុដិសាលាព្រះវិហារជាដើមនិងមិនមានព្រះសង្ឃអ្នកចេះដឹងនិមន្តទៅគង់នៅទីនោះផង។ ដូច្នេះដើម្បីពង្រឹងព្រះពុទ្ធសាសនានៅតាមជាយដែនខ្មែរឲ្យបានលូតលាស់ចំរើន និងដើម្បីជារបងការពារដឹកដីខ្មែរ រដ្ឋាភិបាលនិងពុទ្ធបរិស័ទខ្មែរដែលមានសទ្ធាគួរជួយកសាងវត្តនៅកន្លែងដែលមានខ្មែររស់នៅ បើកន្លែងដែលមានវត្តតែគ្មានសេនាសនៈគ្រប់គ្រាន់គួរជួយកសាងបន្ថែម។ មួយទៀតដើម្បីឲ្យពលរដ្ឋខ្មែរពេញចិត្តទៅរស់នៅតាមជាយដែនឲ្យបានច្រើន គួរធ្វើហេដ្ឋារចនាសម្ពន្ធ ដូចជាផ្លូវថ្នល់ស្ពានសាលារៀន មន្ទីរពេទ្យ បង្កើតផ្សារជាដើម ឲ្យដូចជានៅទីប្រជុំជន។ ប្រទេសជិតខាងតែងរំកិលចូលមកត្រង់ដីទំនេរដែល

គ្មានខ្មែររស់នៅ។ មួយទៀត បើបានធ្វើថ្នល់ព័ន្ធជុំវិញព្រំប្រទល់ដែនជាខ្សែក្រវ៉ាត់ រឹតតែប្រសើរណាស់ទៅទៀត ព្រោះបានជាទំនប់ទប់មិនឲ្យបរទេសរំលោភចូលមកដីខ្មែរបាន។ វត្តអារាមជាដួងព្រលឹងរបស់ខ្មែរ បើមានខ្មែររស់នៅទីណា តែងមានវត្តអារាមនៅទីនោះ ជាទីគោរពសក្ការៈរបស់ខ្លួន។ ដូច្នេះ វត្តទុកជាភ័ស្តុតាងដែលបញ្ជាក់ថា ជាទឹកដីខ្មែរ។ ប្រយោជន៍មួយទៀត បើមានវត្តព្រះពុទ្ធសាសនានៅតាមចុងកាត់មាត់ញកដូច្នេះ អាចជួយបងប្អូនជនជាតិភាគតិច ដែលមានបំណងគោរពព្រះពុទ្ធសាសនា បងប្អូនអាចគោរពបានដោយងាយស្រួល ព្រោះមានវត្តនៅជិតផ្ទះខ្លួន ហើយមិនទុកឱកាសឲ្យសាសនាដទៃ ចូលមកជ្រៀតជ្រែកបានផង។

# ១៣- នាទីរបស់ក្រសួងធម្មការ និងកិច្ចការសាសនា

## អំពើដែលមិនគប្បីធ្វើ

ក្នុងរដ្ឋធម្មនុញ្ញនៃរាជាណាចក្រកម្ពុជាបច្ចុប្បន្នចែងថា ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ដែលរដ្ឋត្រូវតែការពារ និងឧបត្ថម្ភឲ្យចំរើនលូតលាស់ ដូចជាបញ្ជូនសមណនិស្សិតទៅសិក្សានៅប្រទេសដែលកាន់ព្រះពុទ្ធសាសនាជាដើម។ តាមដំណឹងថា ព្រះសង្ឃសមណនិស្សិតដែលទៅសិក្សានៅបរទេសភាគច្រើន លោកដោះស្រាយដោយខ្លួនឯង គ្មានការឧបត្ថម្ភពីក្រសួងធម្មការឡើយ។ អង្គខ្លះសិក្សាចប់ពីបរទេសត្រឡប់មកវិញ គួរទទួលការអបអរសាទរពីក្រសួងធម្មការដោយចាត់តាំងឲ្យព្រះសង្ឃទាំងនោះ មានតំណែងណាមួយ មានធ្វើជាសាស្ត្រាចារ្យជាដើម ដើម្បីអភិវឌ្ឍន៍ព្រះពុទ្ធសាសនាឲ្យរីកចំរើន។ ការប្រកាន់បក្សពួក ហើយដាក់ព្រះសង្ឃដែលមានចំណេះតិចខាងព្រះពុទ្ធសាសនាឲ្យកាន់ការ ពុំអាចធ្វើឲ្យព្រះពុទ្ធសាសនាចំរើនលូតលាស់បានឡើយ។រឿងមួយទៀតដែលគួរចាប់អារម្មណ៍ អ្នកកាន់សាសនាគ្រិស្តមានចំនួនតិចណាស់នៅប្រទេសកម្ពុជា តាមពត៌មានថា មានមួយភាគរយ ចុះហេតុអ្វីបានជាអនុញ្ញាតឲ្យសាងវិហារគ្រិស្តសាសនាច្រើនម្លេះ តើបណ្តាលមកពីហេតុអ្វី? គេនិយាយថា នៅប្រ

ទេសកម្ពុជាឲ្យតែមានដុល្លារ គេធ្វើអ្វីក៏បានដែរ ដូច្នេះបញ្ជាក់ថា ព្រះវិហារគ្រិស្តសាសនាមានចំនួនច្រើន តែអ្នកកាន់មានចំនួនតិចនោះ គេអាចចោទថា ក្រសួងធម្មការប្រព្រឹត្តអំពើពុករលួយ ទទួលសំណូកជាដុល្លារឲ្យគេមកសម្លាប់វប្បធម៌របស់ខ្លួន ដែលខ្លួនត្រូវការពារនោះទៅវិញ។

ពេលនេះ ភារកិច្ចជាចម្បងរបស់ក្រសួងធម្មការ គប្បីឈប់ប្រព្រឹត្តអំពើណា ដែលមិនប្រកបដោយធម៌ ហើយអនុវត្តនូវរាល់កិច្ចការ ដែលនាំឲ្យព្រះពុទ្ធសាសនាមានភាពរឹងមាំនិងលូតលាស់ទៅមុខ គឺរក្សាជំនឿរបស់ប្រជាពលរដ្ឋខ្មែរ គឺព្រះពុទ្ធសាសនាឲ្យបានគង់វង់ ស្របតាមរដ្ឋធម្មនុញ្ញរបស់កម្ពុជាដែលចែងថា ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ។

## អំពីលក្ខខណ្ឌបង្កើតវត្តខ្មែរនៅបរទេស

១. បំណងរក្សាព្រះពុទ្ធសាសនារបស់ខ្លួន។
២. ចំនួនមនុស្សប៉ុន្មាននាក់ដែលគេអាចអនុញ្ញាតឲ្យបង្កើតវត្ត
៣. គ្មានបំណងទាក់ទាញសាសនាដទៃ ឲ្យចូលកាន់ពុទ្ធសាសនាឡើយ។
៤. ទីកន្លែងសាធារណៈ ដូចជាកន្លែងលក់ដូរ កន្លែងរោងចក្រស្រាលៗ ពុំមានជាទីលំនៅដែលគេត្រូវការស្ងប់ស្ងាត់ដេកពួនដើម្បីទៅធ្វើការ។
៥. មានការយល់ព្រមពីអ្នកជិតខាងដោយគ្មានការប្រឆាំង។

នេះជាលក្ខខណ្ឌដែលអាចបង្កើតវត្តបាន តើមន្ត្រីធម្មការមានឲ្យសាសនាដទៃបំពេញលក្ខខណ្ឌនេះ ឲ្យបានគ្រប់គ្រាន់ឬទេ មុននឹងឲ្យបង្កើតវត្តឬព្រះវិហារ? មួយទៀត អ្នកដែលមានសិទ្ធិសុំបង្កើតវត្តនេះ បានតែពលរដ្ឋដែលមានសញ្ជាតិក្នុងប្រទេសនោះ បរទេសដែលពុំមានសញ្ជាតិពុំមានសិទ្ធិសុំបង្កើតវត្តបានឡើយ។ នៅប្រទេសដែលមានសេរីភាពកំពូល គ្មានឃើញគេអនុញ្ញាតឲ្យបរទេសតាំងការិយាល័យផ្សាយសាសនានៅប្រទេសគេឡើយ តើមន្ត្រីធម្មការហេតុអ្វីបានជាអនុញ្ញាតឲ្យបរទេសតាំងការិយាល័យផ្សាយសាសនាគេ ឲ្យអូសទាញអ្នកកាន់សាសនរបស់ខ្លួន? អ្នកណាក៏ដឹងដែរថា សេរីភាពខាងជំនឿ ប៉ុន្តែសេរីភាពនៅក្នុងក្របខ័ណ្ឌច្បាប់របស់ប្រទេស។

សេរីភាពខាងជំនឿ ប៉ុន្តែកុំឲ្យប៉ះពាល់ឬរំលោភលើជំនឿរបស់អ្នកដទៃ។ យ៉ាងណាមិញ ពុំមានជនជាតិខ្មែររត់ទៅរកសាសនាដទៃទេ គឺសាសនាដទៃមកបំបែកបំបាក់ខ្មែរឲ្យលះបង់សាសនារបស់ខ្លួន ទៅជឿសាសនាមួយទៀតដោយល្បិចកិច្ចកលតាមរបៀបដាក់នុយ ទុកជាសម្លាប់ទឹកចិត្តមនោសញ្ចេតនាជំនឿរបស់ខ្មែរ រហូតដល់កុមារាកុមារីដែលជាវ័យពុំទាន់ចេះពិចារណា ក៏ពួកសាសនាគ្រិស្តទៅលួងលោមដែរដោយឲ្យចំណីអាហារ ឬជូនដើរលេងដើម្បីបញ្ឆោតឲ្យជឿគ្រិស្តសាសនា។ នេះជាការរំលោភសិទ្ធិមនុស្ស

យ៉ាងជាក់ស្តែង។ មិនត្រឹមតែនៅទីក្រុងទេ សាសនានេះបាន តាំងការិយាល័យនៅពាសពេញប្រទេសកម្ពុជាទាំងមូល ជាពិសេសនៅខេត្តរតនគិរី មណ្ឌលគិរី ដែលមានជនជាតិភាគតិចរស់នៅច្រើន ដែលនៅសម័យសង្គមរាស្ត្រនិយមទាំងពុទ្ធសាសនិកជនទាំងអាជ្ញាធរខេត្ត ពុំហ៊ានពន្យល់ណែនាំឲ្យចូលកាន់ព្រះពុទ្ធសាសនាឡើយ ដោយទុកសិទ្ធិឲ្យបងប្អូនភាគតិចទាំងនោះ រក្សានូវជំនឿរបស់ខ្លួន។ ឥឡូវនេះ សាសនាគ្រិស្ត ដែលជាជនបរទេសលូកដៃរំលងអំណាចអាជ្ញាធរខ្មែរទៅបញ្ចុះបញ្ចូលអូសទាញបងប្អូនភាគតិចទាំងនោះ ឲ្យលះបង់ជំនឿដើមរបស់ខ្លួន ឲ្យជឿសាសនារបស់គេ បែរជាអាជ្ញាធរខ្មែរធ្វើព្រងើយ ថែមទាំងធ្វើសហការទៀតផង។ អាជ្ញាធរបើកទ្វារផ្ទះឲ្យគេចូល សម្លាប់សាសនា គឺព្រះពុទ្ធសាសនាដែលជាសាសនារបស់ជាតិខ្លួនទៅវិញ។

ការបើកសិទ្ធិខាងជំនឿរបស់ប្រទេសកម្ពុជាសព្វថ្ងៃនេះលើសពី Standard អន្តរជាតិ ក្លាយជាអនាធិបតេយ្យគ្មានអនុវត្តច្បាប់ទម្លាប់ឲ្យបានត្រឹមត្រូវ បណ្តោយឲ្យបរទេសមើលងាយខ្មែរ ចង់សាសនាណាដើរឃោសនាកាន់ខិតប័ណ្ណផ្សាយនៅទីណាក៏បាន។ នៅបរទេសធ្វើអ្វីមួយក៏ស្ថិតនៅក្នុងក្របខ័ណ្ឌច្បាប់ ដូចការផ្សាយសាសនា បើគ្មានច្បាប់អនុញ្ញាតទេ ប៉ូលិសត្រូវចាប់ នេះចំពោះជនបរទេស។

## ១៤- ព្រះពុទ្ធសាសនាចុះខ្សោយ នាំឲ្យប្រទេសកម្ពុជាមានវិបត្តិទៅអនាគត

១. ប្រទេសកម្ពុជាមានឯកភាពខាងសាសនាគឺ ព្រះពុទ្ធសាសនា សម័យសង្គមរាស្ត្រនិយម ប្រជាពលរដ្ឋខ្មែរគោរពបូជាព្រះពុទ្ធសាសនា មានរហូតដល់ទៅ៩៩ភាគរយ។ ព្រះពុទ្ធសាសនាមានពាក្យប្រៀនប្រដៅជាមូលដ្ឋាន គឺធម៌ **អហឹង្សា** ការមិនបៀតបៀន ដែលពុំដែលមានបញ្ហាក្នុងសង្គមដោយបញ្ហាព្រះពុទ្ធសាសនាដែលធ្វើឲ្យរដ្ឋពិបាកគ្រប់គ្រងឡើយ។ ឥឡូវមានសាសនាដទៃមកញុះញង់បំបែកខ្មែរដែលធ្វើឲ្យយើងមានការបារម្ភទៅថ្ងៃក្រោយ អាចមានជំទាស់គ្នារវាងសាសនានិងសាសនា ដោយមានព្រឹត្តិការណ៍ពិភពលោកបានបញ្ជាក់រួចហើយអំពីសាសនានៃប្រទេសខ្លះកំពុងបង្ហូរឈាមគ្នារហូតមកដល់សព្វថ្ងៃ។ ចំពោះព្រះពុទ្ធសាសនាក្នុងប្រវត្តិសាស្ត្រពិភពលោក ពុំដែលបង្ហូរឈាមគ្នាក្នុងបញ្ហាព្រះពុទ្ធសាសនាឡើយ មានតែគេបៀតបៀនខ្លួនវិញ ដូចមហាវិទ្យាល័យ នាលន្ទា នៃប្រទេសឥណ្ឌា ជាមហាវិទ្យាល័យព្រះពុទ្ធសាសនាបានត្រូវសាសនាមួយកំទេចចោល។ ក្រៅពីពុទ្ធសាសនា សាសនាខ្លះមាននយោបាយនៅពីក្រោយ។

២. អាចមានជំទាស់គ្នាក្នុងគ្រួសារអំពីបញ្ហាសាសនាដោយសព្វថ្ងៃនេះ សាសនាគ្រិស្តបានបញ្ចុះបញ្ចូលទាញយក

យុវជនខ្មែរបានខ្លះ ដោយសារមន្ត្រីធម្មការចាត់ការមិនបាន ល្អ។ យុវជនជាកូនដែលកាន់សាសនាដទៃ បង្កើតជម្លោះជា មួយឪពុកម្តាយខ្លួន។ មានឧទាហរណ៍មួយនៅខេត្តកំពង់ធំ យុវជនខ្មែរមួយក្រុមដែលកាន់គ្រិស្តសាសនា បានចូលទៅ វាយព្រះពុទ្ធរូបនៅក្នុងព្រះវិហារនៃវត្តព្រះពុទ្ធសាសនាមួយ បាក់បែកខ្ទេចខ្ទីអស់។ មានវិហារគ្រិស្តសាសនាខ្លះសង់ជិត វត្តព្រះពុទ្ធសាសនា ថ្ងៃក្រោយអាចមានជំនាស់គ្នា ដោយ មន្ត្រីធម្មការចេះតែអនុញ្ញាតច្បាប់ ពុំបានសួរយោបល់អ្នក កាន់ព្រះពុទ្ធសាសនា និងពុំបានគិតឲ្យវែងឆ្ងាយ។

៣. ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា នឹងត្រូវវិនាស ជាលើកទី២ (បន្ទាប់ពីវិនាសលើកទី១នាសម័យខ្មែរក្រហម) ដោយសារស្នាដៃរបស់ក្រសួងធម្មការ និងកិច្ចការសាសនា សព្វថ្ងៃនេះ ហើយការវិនាសពេលនេះពុំអាចរើខ្លួនរួចឡើយ។ ការវិនាសព្រះពុទ្ធសាសនាសម័យ ប៉ុល -ពត អាចរើខ្លួនរួច បន្ទាប់ពីរបបប៉ុល-ពតត្រូវរលាយ ព្រោះខ្មែរទាំងអស់ជាអ្នក ពុទ្ធសាសនា។ ចំណែកការវិនាសពេលនេះ ពុំអាចរើខ្លួនរួច ឡើយ ព្រោះមានបរទេសលូកដៃចូល ទាញយកបរិស័ទ របស់ខ្លួនឲ្យទៅខាងគេ គឺគេសម្លាប់ចិត្តវិញ្ញាណខ្មែរ ហើយ បញ្ចូលចិត្តវិញ្ញាណថ្មី។

## ១៥- អាជ្ញាធរខ្មែរគប្បីពង្រឹងពុទ្ធសាសនា

១. គប្បីពង្រឹងព្រះពុទ្ធសាសនា ដោយពង្រីកពុទ្ធិកសិក្សា ឲ្យរីកចំរើនថែមទៀត និងបញ្ជូនព្រះសង្ឃសមណនិស្សិតឲ្យទៅសិក្សានៅប្រទេសដែលកាន់ពុទ្ធសាសនាដូចគ្នា ដើម្បីបង្កើនចំណេះដល់ព្រះសង្ឃឲ្យទៅជាអ្នកដឹកនាំព្រះពុទ្ធសាសនាដ៏ស្ទាត់ជំនាញ។ ថែមពីលើនេះទៀត គប្បីណែនាំព្រះសង្ឃ ឲ្យគោរពតាមធម៌វិន័យឲ្យបានត្រឹមត្រូវ។ និមន្តព្រះសង្ឃដែលមានសមត្ថភាព ទៅអប់រំកុមារា កុមារី យុវជន យុវនារី នៅតាមវត្តនានា នៅទីក្រុងនិងនៅតាមខេត្តនានា ព្រមទាំងអប់រំសិស្សនិស្សិតនៅតាមសាលារៀនគ្រប់ភូមិសិក្សា ដើម្បីលើកដម្កើងសីលធម៌ឲ្យខ្ពស់ឡើងវិញ។ ចំណែកចៅអធិការ អនុគណ មេគុណ ត្រូវមានចំណេះដឹងនិងគុណធម៌ខ្ពង់ខ្ពស់ ធ្វើជាមេដឹកនាំអប់រំពុទ្ធបរិស័ទខ្មែរ តាមភូមិស្រុក ខេត្ត ក្រុង ឲ្យយល់កាន់តែច្បាស់ឡើងថែមទៀត អំពីតម្លៃនិងខ្លឹមសាររបស់ព្រះពុទ្ធសាសនា និងជួយជំរុញផ្លូវអាណាចក្រ ឲ្យបានលូតលាស់ខាងគុណធម៌និងអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។

២. ត្រូវរៀបចំរចនាសម្ព័ន្ធក្រសួងធម្មការឡើងវិញឲ្យដូចសម័យសង្គមរាស្ត្រនិយម ដែលដាក់មន្ត្រីធម្មការជាអ្នកកាន់និងចេះដឹងព្រះពុទ្ធសាសនាច្បាស់លាស់។

៣. ត្រូវពិនិត្យសើរើសាលាវិហារ និងទីស្នាក់ការនៃ

ពាហិរសាសនាទាំងនោះឡើងវិញដែលបានអនុញ្ញាតច្បាប់មិនប្រក្រតី។ បើពិនិត្យទៅឃើញថា ការអនុញ្ញាតច្បាប់នោះមិនប្រក្រតី ត្រូវដកការអនុញ្ញាតនោះចេញវិញ។

៤. ត្រូវធ្វើច្បាប់គ្រប់គ្រងពាហិរសាសនា។

៥. ត្រូវដាក់ទណ្ឌកម្មដល់មន្ត្រីធម្មការ តាមក្រុងនិងខេត្តដែលបានប្រព្រឹត្តខុស។

៦.ត្រូវពិនិត្យតាមដានអង្គការមនុស្សធម៌ដែលប្រព្រឹត្តខុសមុខនាទីរបស់ខ្លួន អំពីការយកអង្គការមនុស្សធម៌បាំងមុខ ដើម្បីផ្សាយសាសនាខ្លួនបង្ខំខ្មែរឲ្យជឿ។

## ១៦- តម្លៃរបស់ព្រះពុទ្ធសាសនា

តម្លៃរបស់ព្រះពុទ្ធសាសនាដែលមានលក្ខណៈពិសេសផ្សេងពីលទ្ធិនិងសាសនាដទៃគឺ៖

១. មគ្គប្រកបដោយអង្គ៨ ជាមាគ៌ាប្រតិបត្តិដើម្បីរំលត់ទុក្ខដែលហៅថា មជ្ឈិមា បដិបទា ប្រែថា **ផ្លូវកណ្ដាល** ព្រោះច្រានចោលផ្លូវអមខាងទាំងពីរ គឺផ្លូវធូរពេកចិត្តជាប់ក្នុងកាមគុណ៥ និងផ្លូវតឹងពេកគឺប្រតិបត្តិធ្វើបាបកាយ។ ផ្លូវទាំងពីរនេះ សាសនាដទៃតែងតែអនុវត្ត។

២. ព្រះនិព្វាន ជាការរំលត់ទុក្ខពិតប្រាកដ។ ការរំលត់ទុក្ខគឺរំលត់ខន្ធ៥ បញ្ឈប់ជាតិគឺការកើតដែលនាំឲ្យមានជរា និងមរណៈតទៅទៀតក្នុងសង្សារវដ្ដ។ ចំណែកសាសនាដទៃថា ស្ថានសួគ៌និងស្ថានព្រហ្ម ជាស្ថានសុខរបស់ពួកគេ។ ព្រះពុទ្ធសំដែងថា ស្ថានទាំងពីរនេះ ស្ថិតនៅក្រោម **អនិច្ចំ ទុក្ខំ** និង**អនត្តា** តែងវិលកើតវិលស្លាប់គ្មានទីបំផុត មានតែ**ព្រះនិព្វាន**ទេទើបជាបរមសុខពិតប្រាកដ។

៣. ព្រះពុទ្ធត្រាស់ដឹងនូវអរិយសច្ច៤ គឺការពិតដ៏ប្រសើរក្រៃលែង៤ប្រការ គឺសេចក្ដីទុក្ខ ការកើតឡើងនៃខន្ធ៥ត្រូវកំណត់ដឹង ហេតុដែលនាំឲ្យកើតទុក្ខបានដល់តណ្ហា ត្រូវលះបង់ ការរំលត់ទុក្ខបានដល់ព្រះនិព្វានត្រូវធ្វើឲ្យជាក់ច្បាស់ ផ្លូវប្រតិបត្តិទៅកាន់ការរំលត់ទុក្ខបានដល់មគ្គ៨ត្រូវចំរើនឲ្យ

កើតឡើង។

៤. ព្រះពុទ្ធសំដែងអំពីធម៌អហឹង្សាការមិនបៀតបៀន ជាមូលដ្ឋាននៃសុខសន្តិភាពពិភពលោក ព្រោះកាលណាមិនបៀតបៀនគ្នា សង្គ្រាមគ្រប់ប្រភេទពុំកើតឡើងឡើយ។ អង្គការសហប្រជាជាតិបានទទួលស្គាល់តម្លៃព្រះពុទ្ធសាសនា ត្រង់ន័យនេះ បានជាកាលពីថ្ងៃ១០ធ្នូ១៩៩៩ អង្គការសហប្រជាជាតិបានធ្វើសច្ចានុម័តទទួលស្គាល់បុណ្យពិសាខបូជា របស់ព្រះពុទ្ធសាសនា ជាបុណ្យអន្តរជាតិ អាចធ្វើបុណ្យនេះ នៅទីស្នាក់ការអង្គការសហប្រជាជាតិរៀងរាល់ឆ្នាំ។

៥ .ព្រះពុទ្ធសំដែងព្រះធម៌ មានហេតុផលពិត ស្របតាមលក្ខណៈវិទ្យាសាស្ត្រ ដែលគេអាចយកទៅពិសោធឃើញការពិតបាន នៅគ្រប់ទីកន្លែងនិងគ្រប់ពេលវេលា ព្រោះជាសច្ចសកល។

៦. លក្ខណៈពិសេសមួយទៀត ដែលសាសនាដទៃមិនមាន គឺការមិនបង្ខំ។ អក្ខាតារោ តថាគតោ ប្រែថា តថា - គតគ្រាន់តែជាអ្នកប្រាប់ផ្លូវទេ ឯការជឿឬមិនជឿស្រេចលើខ្លួនអ្នក តថាគតមិនបង្ខិតបង្ខំឡើយ។ ព្រះពុទ្ធបានប្រទានយោបល់បន្ថែមទៀតថា មុននឹងជឿពាក្យជនណាម្នាក់ មានតថាគតជាដើម ចូរអ្នកពិចារណានិងធ្វើការពិសោធឲ្យបានល្អិតល្អន់ជាមុនសិន។ នេះជាការបើកសេរីភាពខាងជំនឿរបស់ព្រះពុទ្ធជាម្ចាស់ ស្របនឹងផ្លូវអាណាចក្រនៃប្រទេស

ដែលគោរពប្រជាធិបតេយ្យនិងសិទ្ធិមនុស្ស ក៏គេបើកសិទ្ធិនេះដូចគ្នា។

## ១៧- សេចក្ដីអំពាវនាវ

### សិស្សនិងនិស្សិតខ្មែរទាំងឡាយជាទីរាប់អានក្នុងព្រះធម៌!

វាសនាអនាគតនៃជាតិខ្មែរយើង ត្រូវស្ថិតនៅលើប្អូនៗជាយុវជន និងយុវនារីបន្តវេនពីចាស់ៗ ក្នុងការការពារជាតិនិងកសាងជាតិ ជាពិសេសសង្កត់ធ្ងន់ក្នុងពេលនេះ គឺពង្រឹងវប្បធម៌ខ្មែរ ដែលមានព្រះពុទ្ធសាសនាជាមូលដ្ឋាន។ កាតព្វកិច្ចរបស់ប្អូនក្នុងបឋមវ័យ គឺការខំប្រឹងប្រែងសិក្សារៀនសូត្រឲ្យមានវិជ្ជាកម្រឹតខ្ពស់។ ជាមួយគ្នានោះ ប្អូនគប្បីអប់រំចរិយាសម្បត្តិឲ្យថ្លៃថ្នូរក្នុងរបបសុជីវធម៌និងសីលធម៌ស្របតាមប្រពៃណីទំនៀមទម្លាប់ព្រះពុទ្ធសាសនាខ្មែរ។ប្អូនៗគប្បីលះបង់អំពើអបាយមុខគ្រប់យ៉ាង ល្បែងស្រីល្បែងស្រាល្បែងភ្នាល់ជក់អាភៀនគ្រឿងញៀន លួចប្លន់ ប្រើអំពើហឹង្សាជាដើម ព្រោះអំពើទាំងអស់នេះ ជាឧបសគ្គក្នុងការសិក្សារៀនសូត្រ និងនាំឲ្យខូចកិត្តិយសខ្លួននិងគ្រួសារ ជាពិសេសនាំឲ្យមានបញ្ហាដល់សង្គម។ ក្នុងយុវវ័យដែលមិនទាន់មានការពិសោធក្នុងជីវិត គប្បីស្ដាប់បង្គាប់ឪពុកម្ដាយ គ្រូបង្រៀននិងគោរពច្បាប់របស់រដ្ឋ។ ការមានវិជ្ជាសម្បត្តិនិងចរិយាសម្បត្តិទាំងពីរនេះហើយ ជាគុណសម្បត្តិរបស់ប្អូនប្រុសស្រី។

ការសំខាន់មួយទៀត ដែលប្អូនគប្បីសិក្សាឲ្យយល់

ថែមទៀត គឺព្រះពុទ្ធសាសនាដែលជាមូលដ្ឋាននៃវប្បធម៌ជាតិយើង។ តាមការសិក្សាស្រាវជ្រាវ ព្រះពុទ្ធសាសនាមានខ្លឹមសារដ៏ជ្រាលជ្រៅ ពោលពាក្យពិត ហើយធ្វើឲ្យអ្នកប្រតិបត្តិតាមបានទទួលសេចក្តីសុខរហូតផុតទុក្ខទាំងស្រុងតែម្តង។ ដូចនេះ សូមប្អូនសិស្សនិងនិស្សិតនាំគ្នាថែរក្សាការពារព្រះពុទ្ធសាសនាដែលជាមត៌ករបស់ជាតិយើងឲ្យបានគង់វង់។ ពុំមានសាសនាណាល្អជាងពុទ្ធសាសនាឡើយ បើមានសាសនាណាមួយ ជាពិសេសសាសនាគ្រិស្តមកឃោសនាទាក់ទាញប្អូនៗឲ្យជឿ សូមប្អូនពិចារណាឲ្យម៉ត់ចត់កុំលះបង់សាសនារបស់ខ្លួន ទៅជឿសាសនាគេឡើយ។